- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងពតិមាន
- យោងតាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងពិតមាន

សម្រេច

មាត្រា ១.-

ត្រូវបានប្រគល់ភារកិច្ចជូនលោកស្រី **ខៅ ផល្លីន** ឱ្យបំពេញមុខងារ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា នៃក្រសួងពិតមាន ។

មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ សីហា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច និង ឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៧១៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អគ្គស្នងការនគរបាលជាតិ

សម្រេច

មាត្រា១ៈ ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូននាយនគរបាល នៃនាយកដ្ឋាននគរបាលទេសចរណ៍ និងនាយនគរបាល នៃស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ចំនួន៤២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ការពារសន្តិសុខ សណ្តាប់ធ្នាប់ ជូនភ្ញៀវជាតិ និងអន្តរជាតិ ដូចមានរាយនាមខាងក្រោមនេះ :-

ក-មេដាយមាសការងារ :

១-ឧត្តមសេនីយ៍ត្រី	**ហេង ពៅ**	ស្នងការនគរបាលរាជធានីភ្នំពេញ
២-វរសេនីយ៍ឯក	**ឌុច ដល្លី**	ស្នងការនគរបាល ខេត្តតាកែវ
៣-វរសេនីយ៍ទោ	**ថាន់ ម៉ុន**	នាយការិយាល័យបុគ្គលិក-បណ្តុះបណ្តាល
៤-វរសេនីយ៍ទោ	**ចាន់ សារឿន**	នាយការិយាល័យការពារ និង អន្តរាគមន៍
៥-វរសេនីយ៍ទោ	**សំ ស៊ីយ៉ាន**	ប្រធានអង្គភាពនគរបាលទេសចរណ៍ប្រចាំខេត្តសៀមរាប

ខ-មេដាយប្រាក់ការងារ :

១-វរសេនីយ៍ត្រី	**អៀង ទិចិត្រ**	ប្រធានអង្គភាពនគរបាលទេសចរណ៍រាជធានីភ្នំពេញ
២-វរសេនីយ៍ត្រី	**ស្រូ ឌុន្ធី**	ប្រធានអង្គភាពនគរបាលទេសចរណ៍ ក្រុងព្រះសីហនុ
៣-វរសេនីយ៍ត្រី	**សំ រស្មី**	អនុប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តសៀមរាប
៤-វរសេនីយ៍ត្រី	**សំ ម៉ារឌី**	នាយរងការិយាល័យបុគ្គលិក បណ្តុះបណ្តាល
៥-វរសេនីយ៍ត្រី	**លឹម សុខារស្មី**	នាយរងការិយាល័យរដ្ឋបាលសរុប
៦-វរសេនីយ៍ត្រី	**ជិន សុទុច**	នាយរងការិយាល័យទំនាក់ទំនងសាធារណៈ
៧-អនុសេនីយ៍ឯក	**សារី ឧត្សាន**	នាយផ្នែករដ្ឋបាលសរុប
៨-អនុសេនីយ៍ឯក	**ញ៉ាំ ចាន់ឌី**	នាយផ្នែកអន្តរាគមន៍
៩-អនុសេនីយ៍ឯក	**ពេជ្រ សន្ធាល**	នាយផ្នែកគ្រប់គ្រងមធ្យោបាយ

១០-អនុសេនីយ៍ឯក	សោម សុនីន	នាយផ្នែកសង្គ្រោះ
១១-អនុសេនីយ៍ឯក	សត ណាពេញ	នាយផ្នែករដ្ឋបាលសរុប
១២-អនុសេនីយ៍ឯក	ជឹម សុវណ្ណ	នាយផ្នែកទំនាក់ទំនងសាធារណៈ
១៣-អនុសេនីយ៍ឯក	ជឹម ប្រុសិទ្ធ	នាយផ្នែកពតិមាន
១៤-អនុសេនីយ៍ឯក	ទ៉ាន់ រិទ្ធ	នាយផ្នែកការពារ និង មន្ទភាគមទី
១៥-អនុសេនីយ៍ឯក	ខេង រ៉ា	នាយផ្នែកសង្គ្រោះ
១៦-អនុសេនីយ៍ទោ	ហ៊ាប ណាវុធ	ប្រធានអង្គភាពនគរបាលទេសចរណ៍ខេត្តកណ្តាល
១៧-អនុសេនីយ៍ទោ	អ៊ុន សំអាត	ប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តបាត់ដំបង
១៨-អនុសេនីយ៍ទោ	លឹម លីន	ប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តកំពត
១៩-អនុសេនីយ៍ទោ	អ៊ុំ សុធឿន	ប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តតាកែវ
២០-អនុសេនីយ៍ទោ	យ៉ុន ម៉ុនថេង	ប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តកំពង់ចាម
២១-អនុសេនីយ៍ទោ	គីម យន	ប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តកំពង់ធំ
២២-អនុសេនីយ៍ទោ	កាន់ សាវឿន	ប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តកំពង់ស្ពឺ
២៣-អនុសេនីយ៍ទោ	សួន ញ៉ី	ប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តក្រចេះ
២៤-អនុសេនីយ៍ទោ	កេត វិសុទ្ធរ៉ា	ប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តបន្ទាយមានជ័យ
២៥-អនុសេនីយ៍ទោ	ឃឿន ម៉ុនធឿន	ប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តព្រះវិហារ
២៦-អនុសេនីយ៍ទោ	ជឹម ឆួច	ប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តមណ្ឌលគីរី
២៧-អនុសេនីយ៍ទោ	ម៉ៅ តិរម្យ	ប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តរតនគីរី
២៨-អនុសេនីយ៍ទោ	ជុំ សុភា	ប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តឧត្តរមានជ័យ
២៩-អនុសេនីយ៍ទោ	ផាន់ កណ្ណារ៉ាត	ប្រធានអង្គភាពនគរបាលទេសចរណ៍ ខេត្តកោះកុង
៣០-អនុសេនីយ៍ទោ	ប៉ិច យ៉េង	ប្រធានអង្គភាពនគរបាលទេសចរណ៍ ក្រុងកែប
៣១-អនុសេនីយ៍ទោ	សុខ ដារិន	នាយរងផ្នែកបុគ្គលិក
៣២-អនុសេនីយ៍ទោ	លឹម ចន្ថា	នាយផ្នែកចល័ត
៣៣-អនុសេនីយ៍ទោ	សុខ សុវណ្ណា	នាយរងផ្នែកក្របខ័ណ្ឌបៀវត្ស
៣៤-អនុសេនីយ៍ទោ	សុខ ដារិទ្ធ	នាយរងផ្នែករដ្ឋបាលសរុប
៣៥-អនុសេនីយ៍ទោ	គី សិរិទ្ធ	មន្ត្រី
៣៦-អនុសេនីយ៍ត្រី	អៀន ស្រេង	អនុប្រធានអង្គភាពនគរបាលទេសចរណ៍ ក្រុងប៉ៃលិន
៣៧-អនុសេនីយ៍ត្រី	ជុំ សារិន	នាយរងផ្នែកចល័ត

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គស្នងការនគរបាលជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

Ps-141

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧១៦...អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយថ្នាក់ស្ថាបនាជាតិ** ជូនលោក **ម៉ី ឡាំ** និងលោកស្រី **មេខ ខាំពន្យ** អភិបាលរងខេត្តរតនគីរី ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចំនួន ៨.០៥០.៥០ ដុល្លារ ចូលរួមជួយកសាងខ្លោងទ្វារ វត្តឥសាន្តរតនារាម ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនគីរី។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលខេត្តរតនគីរី ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Ps-153

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ [illegible]

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សភាពាណិជ្ជកម្មរាជធានីភ្នំពេញ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនដល់ សមាជិក សមាជិកា សភាពាណិជ្ជកម្មរាជធានីភ្នំពេញ ចំនួន ៥៧ រូប សំរាប់អាណត្តិទី២ លើកទី១ (ឆ្នាំ២០០២-២០០៥) ដែលបានឧបត្ថម្ភថវិកាក្នុងការជួសជុលទីស្នាក់ការ បំពាក់សម្ភារៈការិយាល័យ និង បំរើកិច្ចប្រជុំ ក្នុង និង ក្រៅប្រទេស ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-អ្នកឧកញ៉ា **សុខ គង់**	ប្រធាន	ចំនួនទឹកប្រាក់	៣៧.៣០០ ដុល្លារ
២-លោកឧកញ៉ា **គង់ ទ្រីវ**	អនុប្រធាន	ចំនួនទឹកប្រាក់	២៧.១០០ ដុល្លារ
៣-លោកឧកញ៉ា **ម៉ែន សារុន**	អនុប្រធាន	ចំនួនទឹកប្រាក់	១៥.៦០០ ដុល្លារ
៤-លោកឧកញ៉ា **ស៊ីន សុខណា**	អនុប្រធាន	ចំនួនទឹកប្រាក់	១៣.៩០០ ដុល្លារ
៥-លោកឧកញ៉ា **លី យ៉ុងផាត់**	អនុប្រធាន	ចំនួនទឹកប្រាក់	១៣.៦០០ ដុល្លារ
៦-លោកឧកញ៉ា **តែ គាំងម៉ីរ**	អគ្គលេខាធិការ	ចំនួនទឹកប្រាក់	១៣.៤០០ ដុល្លារ
៧-លោកឧកញ៉ា **ណាង សុធី**	អគ្គលេខាធិការរង	ចំនួនទឹកប្រាក់	១៣.២០០ ដុល្លារ
៨-លោកឧកញ៉ា **ចាន់ យាង**	ហិរញ្ញិក	ចំនួនទឹកប្រាក់	១៣.១០០ ដុល្លារ
៩-លោក **ម៉ៃ អ៊ុយ**	ហិរញ្ញិករងទី១	ចំនួនទឹកប្រាក់	១២.៣០០ ដុល្លារ
១០-លោកជំទាវឧកញ៉ា **ចាន់ សុផ្លា**	ហិរញ្ញិករងទី២	ចំនួនទឹកប្រាក់	១២.២០០ ដុល្លារ
១១-លោកឧកញ៉ា **គុក អាន**	សមាជិក	ចំនួនទឹកប្រាក់	១២.០០០ ដុល្លារ

១២-លោកឧកញ៉ា	សូ សុវណ្ណ	សមាជិក	ចំនួនទឹកប្រាក់	១១.៥០០ ដុល្លារ
១៣-លោកឧកញ៉ា	ឡាវ ម៉េងឃីន	សមាជិក	ចំនួនទឹកប្រាក់	១១.៤០០ ដុល្លារ
១៤-លោកឧកញ៉ា	សេង ឆាយអ៊ីវ	សមាជិក	ចំនួនទឹកប្រាក់	១១.២០០ ដុល្លារ
១៥-លោកឧកញ៉ា	ឌី ពិសិដ្ឋ	សមាជិក	ចំនួនទឹកប្រាក់	១១.១០០ ដុល្លារ
១៦-លោកឧកញ៉ា	គិត ម៉េង	សមាជិក	ចំនួនទឹកប្រាក់	១០.៩០០ ដុល្លារ
~~១៧-លោកឧកញ៉ា~~	~~ខេង ស្វុតៈ~~	~~សមាជិក~~	~~ចំនួនទឹកប្រាក់~~	~~១០.៧០០ ដុល្លារ~~
១៨-លោកឧកញ៉ា	ម៉ុង ឫទ្ធី	សមាជិក	ចំនួនទឹកប្រាក់	១០.៦០០ ដុល្លារ
១៩-លោកជំទាវឧកញ៉ា	កែវ ម៉ាលី	សមាជិក	ចំនួនទឹកប្រាក់	១០.៥០០ ដុល្លារ
២០-លោកឧកញ៉ា	លឹម ប៊ុនស្វួរ	សមាជិក	ចំនួនទឹកប្រាក់	១០.៥០០ ដុល្លារ
២១-លោកឧកញ៉ា	យុំ ស៊ុយសាង	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	១០.៣០០ ដុល្លារ
២២-លោកឧកញ៉ា	សូ ខ្លួន	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	១០.២០០ ដុល្លារ
២៣-លោកស្រី	ជុង ចាន់សោភា	សមាជិក	ចំនួនទឹកប្រាក់	១០.២០០ ដុល្លារ
២៤-លោក	ឡាយ ម៉េងស៊ុន	សមាជិក	ចំនួនទឹកប្រាក់	១០.១០០ ដុល្លារ
២៥-លោក	ឡុច សារ៉ែត	សមាជិក	ចំនួនទឹកប្រាក់	១០.១០០ ដុល្លារ
២៦-លោក	ហ៊ុំ ហេង	សមាជិក	ចំនួនទឹកប្រាក់	១០.០០០ ដុល្លារ
២៧-លោក	លី គួយ	សមាជិក	ចំនួនទឹកប្រាក់	១០.០០០ ដុល្លារ
២៨-លោក	ជា ខ្លួន	សមាជិក	ចំនួនទឹកប្រាក់	១០.០០០ ដុល្លារ
២៩-លោក	ហោ ម៉ើន	សមាជិក	ចំនួនទឹកប្រាក់	១០.០០០ ដុល្លារ
៣០-លោក	ទី ហួរ	សមាជិក	ចំនួនទឹកប្រាក់	១០.០០០ ដុល្លារ
៣១-លោក	ចេន ជីវ៉ាង	សមាជិក	ចំនួនទឹកប្រាក់	១០.០០០ ដុល្លារ
៣២-លោក	ចាន់ កាយ	សមាជិក	ចំនួនទឹកប្រាក់	១០.០០០ ដុល្លារ
៣៣-លោក	គាំង ម៉េងហ៊ុយ	សមាជិក	ចំនួនទឹកប្រាក់	១០.០០០ ដុល្លារ
៣៤-លោក	គង់ សាង	សមាជិក	ចំនួនទឹកប្រាក់	១០.០០០ ដុល្លារ
៣៥-លោក	ស្វាយ ទុត្តី	សមាជិក	ចំនួនទឹកប្រាក់	១០.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-លោកឧកញ៉ា	ពុង សុវណ្ណ	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៨.៥០០ ដុល្លារ
២-លោក	ទ៉ាន់ ស៊ូអៀង	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៧.៥០០ ដុល្លារ
៣-លោកឧកញ៉ា	ស៊ុង ថៃ	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៧.៣០០ ដុល្លារ
៤-លោកឧកញ៉ា	ផៃ ហុកឈួន	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៧.១០០ ដុល្លារ
៥-លោកឧកញ៉ា	ដួង ឈឹវ	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៦.៩០០ ដុល្លារ
៦-លោកស្រី	ឈឹម ចន្ថី	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៦.៧០០ ដុល្លារ
៧-លោក	ដេវីដ ឆាយឈណាវ៉ា	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៦.៥០០ ដុល្លារ
៨-លោក	Mo Shun Kan	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៦.០០០ ដុល្លារ
៩-លោក	ឌី ម៉េង	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៦.០០០ ដុល្លារ
១០-លោក	ជុំ គឹមស៊ុន	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៦.០០០ ដុល្លារ

១១-លោក	**ចាន់ ហ៊ុយលួង**	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៦.០០០ ដុល្លារ
១២-លោក	**តាំង ខួនសុង**	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៦.០០០ ដុល្លារ
១៣-លោក	**ឡាត់ ខ្មែរ**	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៦.០០០ ដុល្លារ
១៤-លោក	**កែវ វណ្ណា**	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៦.០០០ ដុល្លារ
១៥-លោកឧកញ៉ា	**ស៊ិន សុខា**	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៦.០០០ ដុល្លារ
១៦-លោកជំទាវ	**តាន់ ផល្លី**	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៦.០០០ ដុល្លារ
១៧-លោក	**អ៊ឹង ហុងម៉េង**	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៥.០០០ ដុល្លារ
១៨-លោក	**អៀ ជៀមរះហង**	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៥.០០០ ដុល្លារ
១៩-លោក	**ជា សៀមឡាយ**	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៥.០០០ ដុល្លារ
២០-	Siemens Co., Ltd	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៥.០០០ ដុល្លារ
២១-លោក	**តាន់ ចាំងម៉េង**	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៥.០០០ ដុល្លារ
២២-លោកឧកញ៉ា	**គួនី តាន់ទីហុរណ្ឌ**	សមាជិកទីប្រឹក្សា	ចំនួនទឹកប្រាក់	៥.០០០ ដុល្លារ

មាត្រា២៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

.Tha.47

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧១៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន នៅក្នុងនិងក្រៅប្រទេស ចំនួន ១១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានាជាច្រើន ដូចជាកសាងព្រះវិហារ សាលាបោក្រៃយ៍ ប្រាសាទ កុដិ សាលាបាលី របង ខ្លោងទ្វារ ស្រះទឹក ទូកង ធ្វើផ្លូវគ្រួសក្រហម ប្រវែង១.០០០ម៉ែត្រ និងស្ពាន នៅវត្តសំរោងមានជ័យ ស្ថិតក្នុងឃុំព្រៃគុយ ស្រុកស្ទោងសែន ខេត្តកំពង់ធំ ចំណាយថវិកាសរុបទាំងអស់ ចំនួន ២៥៨.៥០០ ដុល្លារអាមេរិក ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ **ឈាង លី**	ព្រះចៅអធិការវត្តសំរោងមានជ័យ	បច្ច័យ	៤៦.០០០ ដុល្លារ
២-លោកគ្រូសូត្រស្តាំ **ឡេង ប៊ុនសារិទ្ធ**	គង់នៅវត្តសំរោងមានជ័យ	បច្ច័យ	២១.០០០ ដុល្លារ
៣-លោក **ហុង ហាន** និងលោកស្រី **ង៉ែត ធុន**	សប្បុរសជននៅទីក្រុងភ្នំពេញ	ថវិកា	១២៥.៣០០ ដុល្លារ
៤-លោក **ម៉េង ការណាល់** និងលោកស្រី **គិច ហុង**	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកា	២១.៥០០ ដុល្លារ
៥-លោក **ជួង តារា** និងលោកស្រី **ព្រឹំ សុផល**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា	១៧.៥០០ ដុល្លារ
៦-ឧបាសិកា **គ្រួយ គិន**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា	១៥.៣០០ ដុល្លារ
៧-លោក **អៀម ប៊ូ** និងលោកស្រី **អែល តា**	សប្បុរសជន នៅរាជធានីភ្នំពេញ	ថវិកា	១៥.២០០ ដុល្លារ
៨-លោក **ឱុច សន** និងលោកស្រី **ឈុន សារឿន**	សប្បុរសជន នៅរាជធានីភ្នំពេញ	ថវិកា	១៣.៥០០ ដុល្លារ
៩-លោកស្រី **អេង ជីម**	សប្បុរសជន នៅខេត្តកំពង់ធំ	ថវិកា	១១.២០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-ឧបាសក **ប៊ិល ឆាន់**	សប្បុរសជននៅឃុំព្រៃគុយ	ថវិកា	៦.៣០០ ដុល្លារ
២-លោក **ង៉ិម ហ៊ីម** និងលោកស្រី **សុខ នី**	សប្បុរសជននៅឃុំព្រៃគុយ	ថវិកា	៥.៧០០ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
B.tha.40 -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៣០១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការបង្កើតគណៈកម្មការវប្បធម៌កម្ពុជា _ ថៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ : ត្រូវបានបង្កើតគណៈកម្មការវប្បធម៌កម្ពុជា _ ថៃ ដើម្បីជំរុញសហប្រតិបត្តិការវប្បធម៌ រវាងប្រទេសកម្ពុជា និង ប្រទេសថៃ អោយមានប្រសិទ្ធភាព ហើយគណៈកម្មការនេះ មានសមាសភាព ដូចតទៅ ៖

១_ឯកឧត្តម	**ស៊ន សំណាង**		ប្រធាន
២_ឯកឧត្តម	**ស្វាយ ស៊ីថា**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	អនុប្រធាន
៣_ឯកឧត្តម	**ពិត ចំណាន**	តំណាងក្រសួងអប់រំ យុវជន និង កីឡា	អនុប្រធាន
៤_បណ្ឌិត	**អ៊ឹម ច័ន**		អគ្គលេខាធិការ

៥-ឯកឧត្តម **ខៀវ ថាវិកា**	តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៦-ឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសថៃ ឬអ្នកតំណាង		សមាជិក
៧-ឯកឧត្តម **សូ ម៉ារ៉ា**	តំណាងក្រសួងទេសចរណ៍	សមាជិក
៨-អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា		សមាជិក
៩-អគ្គនាយករដ្ឋបាលក្រសួងការពារជាតិ		សមាជិក
១០-អគ្គនាយករដ្ឋបាលក្រសួងមហាផ្ទៃ		សមាជិក
១១-អ្នកតំណាងអាជ្ញាធរទេសចរណ៍		សមាជិក
១២-អ្នកតំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ		សមាជិក
១៣-ឯកឧត្តម **ស៊ុំ ឈុំប៊ុន**		សមាជិក
១៤-ឯកឧត្តម **តិច សំណាង**		សមាជិក
១៥-ឯកឧត្តម **អ៊ឹក សុមេត្ត**		សមាជិក
១៦-ឯកឧត្តម **ឆយ យីហ៊ាង**		សមាជិក
១៧-ឯកឧត្តម **សេ ចន្ទ្រាបុត្រ**		សមាជិក
១៨-ឯកឧត្តម **ឡុង សៀម**		សមាជិក
១៩-ឯកឧត្តម **ពៅ សាមី**		សមាជិក
២០-ឯកឧត្តម **ពេជ កែវ**		សមាជិក
២១-ឯកឧត្តម **មីសែល ត្រាណេ**		សមាជិក
២២-ឯកឧត្តម **ថោង សុជាតិ**		សមាជិក
២៣-បណ្ឌិត **ថ្លាំ ម៉ល់**		សមាជិក
២៤-លោក **យី ធន់**		សមាជិក
២៥-បណ្ឌិត **ឆែល ថោង**		សមាជិក
២៦-បណ្ឌិត **យឹង ហុកឌី**		សមាជិក
២៧-លោក **ស៊ិន សុផាត**		សមាជិក
២៨-លោក **ស៊ុម សៀងឆ៉ាង**		សមាជិក
២៩-លោក **កង ខិម**		សមាជិក
៣០-លោក **ស៊ិន ពិសិដ្ឋ**		លេខាធិការ
៣១-លោក **ឡុង រ៉ាឌុច**		លេខាធិការ

មាត្រា ២ : គណៈកម្មការវប្បធម៌កម្ពុជា-ថៃ មានភារកិច្ចធ្វើការត្រិះរិះពិចារណា និងរៀបចំផែនការសកម្មភាពរួមគ្នាអំពីការអប់រំខាងវប្បធម៌ ប្រវត្តិសាស្ត្រ និងទេសចរណ៍ ក្នុងគោលបំណងកាត់បន្ថយអរិភាព និងបង្កើនការយោគយល់គ្នា តាមរយៈការយល់ដឹងត្រឹមត្រូវទៅវិញទៅមក ដើម្បីពង្រឹង និងអភិវឌ្ឍទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការយូរអង្វែង រវាងប្រទេសកម្ពុជា និងប្រទេសថៃ។

មាត្រា ៣ : គណៈកម្មការវប្បធម៌កម្ពុជា-ថៃ មានការប្រជុំពេញអង្គម្តងក្នុងមួយឆ្នាំ ដើម្បីធ្វើការបូកសរុបកិច្ចសហប្រតិបត្តិការមួយឆ្នាំកន្លងមក និងរៀបចំផែនការសកម្មភាព សម្រាប់ឆ្នាំបន្ទាប់។ ប្រធានគណៈកម្មការមានភារកិច្ចកោះប្រជុំ ក្នុងករណីចាំបាច់ តាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ អនុសាសន៍នៃការប្រជុំរួមនីមួយៗ នឹងត្រូវដាក់ជូនរដ្ឋាភិបាល នៃប្រទេសទាំងពីរ សម្រាប់ការពិចារណា និងចាត់វិធានការអនុវត្ត តាមលទ្ធភាពជាក់ស្តែង។

មាត្រា ៤ : គណៈកម្មការវប្បធម៌កម្ពុជា-ថៃ មានអនុគណៈកម្មការជំនាញចំនួន៣ ជាសេនាធិការ រួមមានផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ និងទេសចរណ៍ ដែលមានសមាសភាព ដូចខាងក្រោមនេះ

-អនុគណៈកម្មការវប្បធម៌:

១-ឯកឧត្តម **នុត ណារ៉ាង**	ប្រធាន
២-លោក **យី ធន់**	អនុប្រធាន
៣-ឯកឧត្តម **នយ យីហ៊ាង**	សមាជិក
៤-បណ្ឌិត **ត្រាំ ម៉ល់**	សមាជិក
៥-ឯកឧត្តម **ពៅ សាមី**	សមាជិក
៦-ឯកឧត្តម **ពេជ្រ ទុំក្រវិល**	សមាជិក
៧-លោកជំទាវ **ខ្លូត ធីតា**	សមាជិក
៨-ឯកឧត្តម **ស៊ឹ ឈុំប៊ុន**	សមាជិក
៩-បណ្ឌិត **ធ សោ**	សមាជិក
១០-បណ្ឌិត **សោម សុម្មនី**	សមាជិក
១១-លោក **ម៉ុញ សារី**	សមាជិក
១២-លោក **ត្រឹង លីម**	សមាជិក
១៣-លោក **អ៊ុច ខាត់**	សមាជិក

១៤-កញ្ញា កែវ សុជាតិ សមាជិក
១៥-លោក នេត សេរី សមាជិក
១៦-លោក មិន ឬទ្ធសបញ្ញារិទ្ធិ លេខាធិការ

-អនុគណៈកម្មការប្រវត្តិសាស្ត្រ:

១-បណ្ឌិត អ៊ឹង ច័ន ប្រធាន
២-ឯកឧត្តម ឆយ អូន អនុប្រធាន
៣-ឯកឧត្តម ឡុង សៀម សមាជិក
៤-ឯកឧត្តម មីសែល ត្រាណេ សមាជិក
៥-បណ្ឌិត ម៉ក់ គីន សមាជិក
៦-បណ្ឌិត ឃីន សុខ សមាជិក
៧-ឯកឧត្តម រស់ ចន្ទ្រាបុត្រ សមាជិក
៨-ឯកឧត្តម ខៀវ ថាវិកា សមាជិក
៩-កញ្ញា អ៊ីន ភគិនី សមាជិក
១០-លោក សាន សុរាចនិត សមាជិក
១១-លោក ធុយ ចាន់ធួន សមាជិក
១២-លោក ជិន សុជាតិ លេខាធិការ

-អនុគណៈកម្មការទេសចរណ៍:

១-ឯកឧត្តម សូ ម៉ារ៉ា ប្រធាន
២-ឯកឧត្តម ពេជ កែវ អនុប្រធាន
៣-ឯកឧត្តម អ៊ុក សូមេត្ត សមាជិក
៤-ឯកឧត្តម ពិត ចំណាន សមាជិក
៥-ឯកឧត្តម លី គីមសុខ សមាជិក
៦-បណ្ឌិត អ៊ុខ ជិនណារី សមាជិក
៧-លោក ម៉ី ម៉ារ៉ាឌី សមាជិក
៨-លោក ឱម ផារិន តំណាងសមាគមទីភ្នាក់ងារទេសចរណ៍ សមាជិក
៩-លោក ធី សុគន្ធា តំណាងសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាជិក
១០-អ្នកតំណាងក្រុមហ៊ុនអាកាសចរណ៍សៀមរាបអ៊ែរវ៉េ សមាជិក
១១-លោក ស្រ៊ុន ហួរ សមាជិក
១២-កញ្ញា គីម កែវកល្យាណ លេខាធិការ

មាត្រា ៥ : អនុគណៈកម្មការជំនាញនីមួយៗ មានភារកិច្ច ដូចខាងក្រោមនេះ

-អនុគណៈកម្មការវប្បធម៌:

-សហការជាមួយអនុគណៈកម្មការវប្បធម៌ខាងភាគីថៃ ដើម្បីអនុវត្តគម្រោងទាក់ទងនឹងវប្បធម៌ ដែលមានចែងនៅក្នុង "យុទ្ធសាស្ត្ររួម"

-សហការជាមួយអនុគណៈកម្មការវប្បធម៌ខាងភាគីថៃ ក្នុងការលើកគម្រោងសហប្រតិបត្តិការផ្នែកវប្បធម៌ យ៉ាងតិចមួយគម្រោងក្នុងមួយឆ្នាំ ជូនទៅគណៈកម្មការវប្បធម៌កម្ពុជា-ថៃ សម្រាប់ធ្វើការពិចារណា ក្នុងឱកាសនៃការប្រជុំពេញអង្គប្រចាំឆ្នាំ

-ចូលរួមក្នុងសកម្មភាពផ្សេងៗ ដែលមានសារៈសំខាន់សម្រាប់ការជំរុញសហប្រតិបត្តិការវប្បធម៌ រវាងប្រទេសទាំងពីរ

-ប្រមូលឯកសារចាស់និងថ្មីស្តីពីទំនាក់ទំនងវប្បធម៌កម្ពុជា-ថៃ

-ធ្វើតុល្យការលើទំនាក់ទំនងសហប្រតិបត្តិការផ្នែកវប្បធម៌ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

-អនុគណៈកម្មការប្រវត្តិសាស្ត្រ:

-សហការជាមួយអនុគណៈកម្មការប្រវត្តិសាស្ត្រខាងភាគីថៃ ដើម្បីអនុវត្តគម្រោងទាក់ទងនឹងប្រវត្តិសាស្ត្រ ដែលមានចែងនៅក្នុង "យុទ្ធសាស្ត្ររួម"

-សហការជាមួយអនុគណៈកម្មការប្រវត្តិសាស្ត្រខាងភាគីថៃ ក្នុងការលើកគម្រោងសហប្រតិបត្តិការផ្នែកប្រវត្តិសាស្ត្រ យ៉ាងតិចមួយគម្រោងក្នុងមួយឆ្នាំ ជូនទៅគណៈកម្មការវប្បធម៌កម្ពុជា-ថៃ សម្រាប់ធ្វើការពិចារណា ក្នុងឱកាសនៃការប្រជុំពេញអង្គប្រចាំឆ្នាំ

-ចូលរួមក្នុងសកម្មភាពផ្សេងៗ ដែលមានសារៈសំខាន់សម្រាប់ការជំរុញសហប្រតិបត្តិការវប្បធម៌ រវាងប្រទេសទាំងពីរ

-ប្រមូលឯកសារចាស់និងថ្មីស្តីពីទំនាក់ទំនងប្រវត្តិសាស្ត្រកម្ពុជា-ថៃ

-ធ្វើតុល្យការលើទំនាក់ទំនងសហប្រតិបត្តិការផ្នែកប្រវត្តិសាស្ត្រ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

-អនុគណៈកម្មការទេសចរណ៍:

-សហការជាមួយអនុគណៈកម្មការទេសចរណ៍ខាងភាគីថៃ ដើម្បីអនុវត្តគម្រោងទាក់ទងនឹងទេសចរណ៍ ដែលមានចែងនៅក្នុង "យុទ្ធសាស្ត្ររួម"

-សហការជាមួយអនុគណៈកម្មការទេសចរណ៍ខាងភាគីថៃ ក្នុងការលើកគម្រោងសហប្រតិបត្តិការផ្នែកទេសចរណ៍ យ៉ាងតិចមួយគម្រោងក្នុងមួយឆ្នាំ ជូនទៅគណៈកម្មការវប្បធម៌កម្ពុជា-ថៃ សម្រាប់ធ្វើការពិចារណា ក្នុងឱកាសនៃការប្រជុំពេញអង្គប្រចាំឆ្នាំ

-ចូលរួមក្នុងសកម្មភាពផ្សេងៗ ដែលមានសារៈសំខាន់សម្រាប់ការជំរុញសហប្រតិបត្តិការវប្បធម៌ រវាងប្រទេសទាំងពីរ

-ប្រមូលឯកសារចាស់និងថ្មីស្តីពីទំនាក់ទំនងទេសចរណ៍កម្ពុជា-ថៃ

-ធ្វើតុល្យការលើទំនាក់ទំនងសហប្រតិបត្តិការផ្នែកទេសចរណ៍ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

មាត្រា ៦ : អនុគណៈកម្មការជំនាញនីមួយៗ ត្រូវធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារ ដូចមានចែងក្នុងមាត្រា ៥ និងលើកសំណើផ្សេងៗ ជូនប្រធានគណៈកម្មការវប្បធម៌កម្ពុជា-ថៃ ដែលត្រូវធ្វើការបូកសរុបជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។

មាត្រា ៧ : គណៈកម្មការវប្បធម៌កម្ពុជា-ថៃ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅរាជបណ្ឌិតសភាកម្ពុជា។

មាត្រា ៨ : ថវិកាសម្រាប់ធានាដំណើរការក្នុងលេខាធិការដ្ឋាន និងក្នុងការប្រជុំនានា ជាថវិកាជាតិ តាមគម្រោងដែលស្នើឡើងដោយគណៈកម្មការខាងភាគីកម្ពុជា តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។

មាត្រា ៩ : គណៈកម្មការនេះ មានសិទ្ធិទទួលជំនួយគ្រប់ផ្នែក ពីប្រភពផ្សេងៗទៀត។

មាត្រា ១០ : សមាជិកគណៈកម្មការ និងអនុគណៈកម្មការ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។

មាត្រា ១១ : គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា របស់រាជបណ្ឌិតសភាកម្ពុជា។

មាត្រា ១២ : អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៣ ស្តីពីការបង្កើតគណៈកម្មការកម្ពុជា សំរាប់ស្រាវជ្រាវរួមគ្នាជាមួយភាគីថៃ អំពីវិស័យវប្បធម៌ និង អនុក្រឹត្យលេខ ២៦៦

អនក្រ.តត ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងសមាជិកបន្ថែម នៃគណៈកម្មការកម្ពុជា សំរាប់ស្រាវជ្រាវរួមគ្នាជាមួយភាគីថៃអំពីវិស័យវប្បធម៌ ព្រមទាំងបទប្បញ្ញត្តិណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ និងសមាជិកគណៈកម្មការដែលមាននាមចែងក្នុងមាត្រា ១ និង ៤ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេច និងឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១៣*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៧៤០...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៛

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ០៤រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តកោះតាម៉ៅ ឃុំសួរគង ស្រុកកងមាស ខេត្តកំពង់ចាម ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

១-ព្រះតេជគុណ **អៀន សុធាលី**	ចៅអធិការវត្តកោះតាម៉ៅ	បច្ច័យចំនួន ៤៣.០០០ ដុល្លារ
២-លោក **ចេង គុកម៉េង**	នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ៤៥.០០០ ដុល្លារ
៣-លោកស្រី **ឡៅ ជុនអេង**	នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ៤១.០០០ ដុល្លារ
៤-លោក **ម៉ាវ គុយ**	ប្រធានគង្វាលអង្គការស្ពានកម្ពុជា-ហូឡង់ដ៍	ថវិកា ចំនួន ២០.៣៤៩ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
SR.149 -ឯកសារ-កាលប្បវត្តិ

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៧៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន០៤រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលសាធារណៈផ្សេងៗ ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ឯកឧត្តម **ស៊ីវន្ត សារុន** នៅក្រុងភ្នំពេញ ថវិកាចំនួន ១៩.០១២ ដុល្លារ

២-លោកជំទាវ **អ៊ឹន សុគន្ធា** នៅក្រុងភ្នំពេញ ថវិកាចំនួន ១១.៣៨៩ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-ឯកឧត្តម **យស់ សុន** នៅក្រុងភ្នំពេញ ថវិកាចំនួន ៥.២២៣ ដុល្លារ

២-ឯកឧត្តម **អៀម សារុំ** នៅក្រុងភ្នំពេញ ថវិកាចំនួន ៥.១៥០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៥៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក កែវ សឿន ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

មាត្រា ២ : ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រី ចំនួន ០៤ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដូចមានរាយនាមខាងក្រោម :

១- លោក សាណែត ចន្ថូនា ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

២- លោក យូ សុឆ្មី ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ

៣- លោក សុន សែ ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គាធិការដ្ឋាន

៤- លោក ឡៅ ទើង ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានស្តារលទ្ធភាពពលកម្ម ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោក Shyam K.Bhurtel ទីប្រឹក្សាគាំពរងគាំទ្រគោលនយោបាយវិមជ្ឈការ របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា **(DSP/UNDP)** ដែលមានស្នាដៃល្អក្នុងការគាំទ្រដល់ការអនុវត្តន៍គោលនយោបាយវិមជ្ឈការ នៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
  (ដើម្បីជូនជ្រាប)
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៣៧៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ស ម្រ េ ច

មាត្រា ១ : ត្រូវបានតែងតាំងលោក **សូ ត្រែ** ជាប្រធាន**ផ្នែករដ្ឋបាល គ្រប់គ្រង និងហិរញ្ញកិច្ច** នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាអ្នកច្បាប់ មានឋានៈ**ស្មើប្រធាននាយកដ្ឋាន** ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
៚
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ១៣រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តគីរីវនារាម និង វត្តពោធិមង្គល ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

ក.មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ **ឆឹម ណាក់**	គង់នៅវត្តគីរីវនារាម	ថវិកាចំនួន ១២៥.៧៦០	ដុល្លារ
២-ព្រះតេជគុណ **អ៊ូ ស៊ាង**	ចៅអធិការវត្តពោធិមង្គល	ថវិកាចំនួន ២១.៤០០	ដុល្លារ
៣-លោក **កាំង យូឡា**	សប្បុរសជនខ្មែររស់នៅប្រទេសអូស្ត្រាលី	ថវិកាចំនួន ៣៥.១៤៤	ដុល្លារ
៤-លោក **សុខ សៀកឡេង**	សប្បុរសជននៅក្រុងភ្នំពេញ	ថវិកាចំនួន ២៣.០០០	ដុល្លារ
៥-លោក **ឆាយ លឹមគង់**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១០.០០០	ដុល្លារ

ខ.មេដាយសំរិទ្ធស្ថាបនាជាតិ :

១-លោកយាយ **គោគ លឹមគួន**	សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា	ថវិកាចំនួន ៤.៣១០	ដុល្លារ
២-លោកយាយ **ហង្ស យ៉េន**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៣.៨០០	ដុល្លារ
៣-លោក **ជួន លាងសេង**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៣.១០០	ដុល្លារ
៤-លោក **ជឹង ឆាងសេង**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៤.២៤៨	ដុល្លារ
៥-លោក **ចង ឡេងសេងលី**	សប្បុរសជននៅក្រុងភ្នំពេញ	ថវិកាចំនួន ៣.១០០	ដុល្លារ

៦-លោក	**តុល ឃាត់**	សប្បុរសជននៅក្រុងភ្នំពេញ	ថវិកាចំនួន	៣.០០០ ដុល្លារ
៧-លោកស្រី	**ហ៊ុល គន**	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន	២.០០០ ដុល្លារ
៨-លោក	**កៅ សុខអាន**	អភិបាលស្រុក ស្ទឹងត្រង់	ថវិកាចំនួន	១.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច

SR.153 -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧៧៦...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
៙៚
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជប៉ុន និង កម្ពុជា ចំនួន០៨រូប ដែលបានបរិច្ចាគថវិកាជួយកសាងអគារសិក្សា ចំនួន០២ខ្នង រួមជាមួយ របង ខ្លោងទ្វារ បន្ទប់ទឹក អណ្តូងទឹក និង សម្ភារៈសិក្សា គ្រប់ប្រភេទ នៅសាលាបឋមសិក្សា *គុម៉ាម៉ូតូឡាយអិនស៍អង្គសរ៉ែ* ឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ ចំណាយអស់ទឹកប្រាក់ចំនួន ៩៥.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម :-

១-លោក MAITA KUNIHIKO ប្រធានសមាគម *គុម៉ាម៉ូតូ ឡាយអិនស៍ក្លិប* .

២-លោក MUTO KOKI ប្រធានសមាគម *គុម៉ាម៉ូតូ ឡាយអិនស៍ក្លិប*

៣-លោក YONEZAWA YOSHIKAZU

៤-លោក YANAGISAKO HIDEYASU

៥-លោក OKUZAWA SHUN

៦-លោក វេជ្ជបណ្ឌិត **ឌេព លន់**

៧-លោកជំទាវ **ម៉ុច សុខចំនួ** និង ស្វាមី

៨-លោក **អ៊ុំ សារីក់**

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច /

SR.180 -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៧៤៣ អនក.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសុវត្ថារា

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកា នៃ ***ភ្នំពេញសិនត្រល់ ឡាយអិនស៍ក្លិប*** ចំនួន១៥រូប ដែលមានគុណបំណាច់ខ្ពស់ និងស្នាដៃល្អ ក្នុងការចូលរួមជួយជម្រុញការអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋកម្ពុជា ដូចមានរាយនាមខាងក្រោម :-

ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ :

១-លោក **សោម សុខរ៉ាឌី**	ប្រធាន ***ភ្នំពេញសិនត្រល់ឡាយអិនស៍ក្លិប*** អាណត្តិ ២០០១-២០០២ និង អាណត្តិ ២០០២-២០០៣
២-Mrs. ASAKURA MASAKO	(នាមកំណើត លោកស្រី **ជូ ដារ៉ារ៉េត**) ប្រធាន ***ភ្នំពេញសិនត្រល់ ឡាយអិនស៍ក្លិប*** អាណត្តិ ២០០៤-២០០៥ និង ២០០៥-២០០៦
៣-ឯកឧត្តម **គាំម គុសល**	ប្រធានកិត្តិយស ***ភ្នំពេញសិនត្រល់ឡាយអិនស៍ក្លិប***

ខ. មេដាយសុវត្ថារា ថ្នាក់ សេនា :

១-លោក TAMABAYASHI TAKEO (នាមកំណើត ជូ គីរី) សមាជិកស្ថាបនិក

២-លោក គៀង គឹមអាន អគ្គលេខាធិការ *ភ្នំពេញសិនត្រល់ឡាយអិនស័ក្ខិប*

៣-លោកស្រី ពាង សុវណ្ណារី អគ្គហិរញ្ញិក *ភ្នំពេញសិនត្រល់ឡាយអិនស័ក្ខិប*

៤-ឯកឧត្តម ឆា ចំនួលីដា សមាជិកស្ថាបនិក

៥-ឯកឧត្តម ចាយ ប៊ូរិន សមាជិកកិត្តិយស

គ. មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ :

១-លោកស្រី វេជ្ជបណ្ឌិត លី ស្រីទីណា សមាជិកាស្ថាបនិក

២-លោក ត្រៀង ឈៀង សមាជិកស្ថាបនិក

៣-លោក ជា ឈុល សមាជិកស្ថាបនិក

៤-លោក ឃុនរ្ស ប៊ុណ្ណាក់ សមាជិកស្ថាបនិក

៥-លោក គូ សារម៉ីឌី កម្មិក:សមាជិក

៦-លោក កុសល ខេមរិន្ទ កម្មិក:សមាជិក

៧-លោក សំអឿន សុភាវង្ស កម្មិក:សមាជិក

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៨៧ សសរ

សេចក្ដីសម្រេច

ស្ដីពីកំណែតម្រូវឈ្មោះគណៈកម្មការដឹកនាំការងារអភិវឌ្ឍន៍ផ្នែកឯកជន និងការបន្ថែមសមាសភាពសមាជិកនៃអនុគណៈកម្មាធិការសហគ្រាសធុនតូច និងមធ្យម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងសម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល និងជាសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៣ /នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្ដីសម្រេចលេខ ៤៤ សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការបង្កើតគណៈកម្មការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- អនុលោមតាមតម្រូវការចាំបាច់នៃការងារ

សម្រេច

ប្រការ១: ត្រូវបានកែតម្រូវឈ្មោះ " គណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន " ដែលមានចែងក្នុងសេចក្ដីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤ ជា " គណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន " ។ រាល់ពាក្យ " គណៈកម្មការ " ដែលមានចែងក្នុងសេចក្ដីសំរេចលេខ ៤៦ សសរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ២០០៤ ត្រូវបានជំនួសដោយពាក្យ " គណៈកម្មាធិការ " ។ ឯពាក្យ " អនុគណៈកម្មការ " ដែលមានចែងក្នុងសេចក្ដីសំរេចលេខ ៤៦ សសរ ត្រូវបានជំនួសដោយពាក្យ " អនុគណៈកម្មាធិការ " ។

ប្រការ២: ត្រូវបានបន្ថែមសមាសភាពសមាជិកអនុគណៈកម្មាធិការសហគ្រាសធុនតូច និងមធ្យម ដូចតទៅៈ

១- ឯកឧត្ដម **ពេជ សោភ័ន** រដ្ឋលេខាធិការនៃក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

២- ឯកឧត្ដម **អ៊ឹង ចន្ថា** រដ្ឋលេខាធិការ នៃក្រសួងអភិវឌ្ឍន៍ជនបទ

ប្រការ៣: សេចក្ដីសំរេចណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្ដីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៤: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ខាងលើ ត្រូវអនុវត្តសេចក្ដីសំរេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ សីហា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២ និងប្រការ៤
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៣៣......សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មាធិការលុបបំបាត់ឱសថក្លែងក្លាយ និង សេវាសុខាភិបាលខុសច្បាប់ដើម្បីកាត់បន្ថយភាពក្រីក្រ

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃ៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទ និងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតអោយជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

សម្រេច

ប្រការ ១.-

បង្កើតគណៈកម្មាធិការមួយដែលមានឈ្មោះ គណៈកម្មាធិការលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ដែលមានវិសាលភាពទូទាំងព្រះរាជាណាចក្រកម្ពុជាសម្រាប់កាត់បន្ថយភាពក្រីក្រ ។

គណៈកម្មាធិការមានគណៈកម្មការ២ ៖

១.១ គណៈកម្មការអន្តរក្រសួង

គណៈកម្មការអន្តរក្រសួងមានសមាសភាពដូចខាងក្រោម ៖

១. រដ្ឋមន្ត្រីក្រសួងសុខាភិបាល	ជាប្រធាន
២. រដ្ឋលេខាធិការក្រសួងសុខាភិបាល	០១ រូបជាអនុប្រធានអចិន្ត្រៃយ៍
៣. អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល	០១ រូបជាអនុប្រធាន
៤. អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ	០១ រូបជាអនុប្រធាន
៥. អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌	០១ រូបជាសមាជិក
៦. អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន	០១ រូបជាសមាជិក
៧. អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	០១ រូបជាសមាជិក
៨. អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា	០១ រូបជាសមាជិក
៩. អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	០១ រូបជាសមាជិក
១០.អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	០១ រូបជាសមាជិក
១១.អភិបាលរងរាជធានីភ្នំពេញ	០១ រូបជាសមាជិក
១២.ប្រធាននាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល	ជាសមាជិក
១៣.ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង នៃក្រសួងសុខាភិបាល	ជាលេខាធិការ

១.២ គណៈកម្មការខេត្ត-ក្រុង

គណៈកម្មការខេត្ត ក្រុង មានសមាសភាពដូចខាងក្រោម ៖

១. អភិបាលរងខេត្ត ក្រុង	ជាប្រធាន
២. ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង	ជាអនុប្រធានអចិន្ត្រៃយ៍
៣. អនុប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង	០១ រូបជាសមាជិក

៤. តំណាងអយ្យការតុលាការខេត្ត ក្រុង	០១ រូបជាសមាជិក
៥. ស្នងការនគរបាលខេត្ត ក្រុង	ជាសមាជិក
៦. ប្រធានមន្ទីរព័ត៌មានខេត្ត ក្រុង	ជាសមាជិក
៧. ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង	ជាសមាជិក
៨. ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង	ជាសមាជិក
៩. ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្រុង	ជាសមាជិក
១០.ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត ក្រុង	ជាសមាជិក
១១.ប្រធានសាខាកាំកុងត្រូលខេត្ត ក្រុង	ជាសមាជិក
១២.ប្រធានការិយាល័យបច្ចេកទេសនៃមន្ទីរសុខាភិបាល	ជាសមាជិក
១៣.ប្រធានការិយាល័យឱសថ និងសុវត្ថិភាពចំណីអាហារ	ជាលេខាធិការ

ប្រការ ២.-

គណៈកម្មាធិការលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រ មានតួនាទី និងភារកិច្ច ដូចតទៅ ÷

- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរក្រសួង និងអន្តរជាតិដើម្បីលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ដែលបច្ចុប្បន្នកំពុងកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជា
- ខិតខំស្វែងរកប្រភពនៃឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់
- ចាត់វិធានការប្រកបដោយប្រសិទ្ធភាពក្នុងការត្រួតពិនិត្យជាប្រចាំដើម្បីឃាត់ទុក បំផ្លាញចោល និងទប់ស្កាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ឈានទៅលុបបំបាត់ជាស្ថាពរ
- ផ្សព្វផ្សាយ អប់រំ និងលើកកម្ពស់ការយល់ដឹងដល់សាធារណជន អំពីគ្រោះថ្នាក់នៃការប្រើប្រាស់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់
- រៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីវិនិច្ឆ័យទោសតាមច្បាប់ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើស ។

ប្រការ ៣.-

គណៈកម្មការអន្តរក្រសួងលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាលដើម្បីសម្រួលការងារ ។

គណៈកម្មការខេត្ត ក្រុង លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រ មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង ដើម្បីសម្រួលការងារ ។

ប្រការ ៤.-

គណៈកម្មការអន្តរក្រសួងលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រ មានលេខាធិការដ្ឋាននៅក្រសួងសុខាភិបាល ។

គណៈកម្មការខេត្ត ក្រុង លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រ មានលេខាធិការដ្ឋាននៅមន្ទីរសុខាភិបាលខេត្ត ក្រុង ។

ប្រការ ៥.-

បណ្តាសមាជិកគណៈកម្មការអន្តរក្រសួង និងសមាជិកគណៈកម្មការខេត្ត ក្រុង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានដើម្បីរាយការណ៍ពីសកម្មភាព និងលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

ប្រការ ៦.-

រាល់ចំណាយរបស់គណៈកម្មាធិការជាបន្ទុករបស់ក្រសួងសុខាភិបាល ។

ប្រការ ៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុងពាក់ព័ន្ធ និងសមាសភាព ដូចក្នុងប្រការ១ខាងលើនេះ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ ក្រសួង ស្ថាប័ន
- ដូចប្រការ១
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤៩៥ សហវ

ភ្នំពេញ ថ្ងៃទី១៣ខែសីហា ឆ្នាំ ២០០៥

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួម សំរាប់អនុវត្តគំរោងជំនួយរបស់ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ៣១៩ សហវ.ប.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការអនុវត្តន៍វិធាន និងបទប្បញ្ញត្តិក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ០៤៥ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តន៍វិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ១៣២ សហវ.ហក.ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការចំណាយជំពូក ៥០ ប្រការ ០២ "ការរួមចំណែករបស់រាជរដ្ឋាភិបាលចំពោះការវិនិយោគដោយផ្ទាល់ពីក្រៅប្រទេស (មូលនិធិបដិភាគ)"
- យោងតាមតំរូវការចាំបាច់របស់ក្រសួង និងដោយមានការព្រមព្រៀងជាមួយធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី

សំរេច

ប្រការ១: ដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសំរាប់អនុវត្តគំរោងជំនួយពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ីដូចដែលមានខ្លឹមសារដូចមានភ្ជាប់ជាមួយប្រកាសនេះ ។

ប្រការ២: នីតិវិធីនេះនឹងត្រូវអនុវត្តសំរាប់គំរោងហិរញ្ញប្បទានពីបរទេសផ្សេងទៀត ប្រសិនបើមានការព្រមព្រៀងពីអ្នកផ្តល់ ។

ប្រការ៣: អគ្គលេខាធិការដ្ឋាន ខុទ្ទកាល័យ គ្រប់នាយកដ្ឋានពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង គ្រប់ភ្នាក់ងារប្រតិបត្តិគំរោងពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៧៧១ ឧស្សា.សឧក.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៥

ប្រកាស
ស្តីពី
លក្ខខណ្ឌទូទៅនៃការផ្តល់អាជ្ញាប័ណ្ណប្រើសញ្ញាបញ្ជាក់ផលិតផល

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីស្តង់ដាឧស្សាហកម្មកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតម្លើងការិយាល័យអាស៊ាន និងការិយាល័យស្តង់ដាឧស្សាហកម្មទៅជានាយកដ្ឋានសហប្រតិបត្តិការនិងការងារអាស៊ាន និងជានាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជានៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- យោងទៅតាមតំរូវការជាក់ស្តែង

<u>សំរេច</u>

ប្រការ ១ : កំណត់លក្ខខណ្ឌទូទៅនៃការផ្តល់អាជ្ញាប័ណ្ណប្រើសញ្ញាបញ្ជាក់ផលិតផលសំរាប់អនុវត្តក្នុងការបញ្ជាក់ផលិតផលដែលប្រតិបត្តិដោយនាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ ២ : សញ្ញាបញ្ជាក់ផលិតផលគឺជាសញ្ញាស្តង់ដាឧស្សាហកម្មកម្ពុជា ដែលបញ្ជាក់ពីការអនុលោមតាមការតំរូវនៃស្តង់ដាឧស្សាហកម្មកម្ពុជា ដូចដែលបានកំណត់នៅក្នុងប្រកាសលេខ១១២ ឧរថ.សឧក.ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីអំពីសញ្ញាសំគាល់ស្តង់ដាឧស្សាហកម្មកម្ពុជា ។

ប្រការ ៣ : ការស្នើសុំ

១- រាល់ការស្នើសុំអាជ្ញាប័ណ្ណប្រើសញ្ញាបញ្ជាក់ផលិតផល ត្រូវដាក់សំណើទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយត្រូវបំពេញទំរង់បែបបទដូចមាននៅក្នុង **ឧបសម្ព័ន្ធ ១** ។

២-នៅពេលទទួលពាក្យស្នើសុំ នាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា ត្រូវចាត់មន្ត្រីមានសមត្ថកិច្ចឱ្យចុះពិនិត្យដល់ទីកន្លែង និងតំរូវឱ្យអ្នកស្នើសុំ :

ក- បង្ហាញភស្តុតាងដែលអាចទទួលយកបានដោយនាយកដ្ឋានគឺ :

- ផលិតផល ឬដំណើរការផលិតកម្មដែលត្រូវស្នើសុំអាជ្ញាប័ណ្ណបានអនុលោមទៅតាមស្តង់ដាឧស្សាហកម្មកម្ពុជាណាមួយ
- ប្រព័ន្ធធានាគុណភាពមួយ ដែលធានាបានយ៉ាងគ្រប់គ្រាន់ថា ផលិតផល ឬដំណើរការផលិតកម្មដែលត្រូវស្នើសុំអាជ្ញាប័ណ្ណ នឹងបន្តអនុលោមទៅតាមស្តង់ដានោះ

ខ- បង្ហាញគ្រប់សម្ភារៈបរិក្ខាប្រើប្រាស់ទាំងអស់ដល់មន្ត្រីមានសមត្ថកិច្ចនៅគ្រប់កន្លែងទាំងអស់របស់អ្នកស្នើសុំសំរាប់ :

- ធ្វើការផ្ទៀងផ្ទាត់នូវភស្តុតាងដែលផ្តល់ឱ្យដោយអ្នកស្នើសុំ
- ធ្វើការត្រួតពិនិត្យបែបផែននិងដំណើរការផលិតកម្ម និងការកត់ត្រាទាំងអស់ដែលពាក់ព័ន្ធទៅនឹងផលិតផលនោះ
- ទទួលយកពត៌មានផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងការស្នើសុំ

គ- ផ្តល់គំរូផលិតផលសំរាប់ធ្វើតេស្ត ។

ប្រការ ៤ : ចាប់ពីបានទទួលពាក្យស្នើសុំស្របតាមប្រការ៣ ប្រសិនបើនាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជាបានពិនិត្យឃើញថា ផលិតផលនោះបានអនុលោមតាមស្តង់ដាណាមួយហើយ នាយកដ្ឋានត្រូវជូនដំណឹងដល់អ្នកស្នើសុំដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រើសញ្ញាបញ្ជាក់ផលិតផល រួចចេញវិញ្ញាបនប័ត្រអនុលោមស្តង់ដាដូចមានគំរូនៅក្នុង **ឧបសម្ព័ន្ធ ២**។

យោងវិញ្ញាបនប័ត្រអនុលោមស្តង់ដានេះ ក្រសួងត្រូវផ្តល់អាជ្ញាប័ណ្ណ ដូចមានគំរូនៅក្នុង ឧបសម្ព័ន្ធ ៣ ដល់អ្នកស្នើសុំ ដើម្បីបានប្រើប្រាស់សញ្ញាបញ្ជាក់ផលិតផលតាមកាលកំណត់ និង លក្ខខណ្ឌដូចខាងក្រោម :

១- អាជ្ញាប័ណ្ណមិនត្រូវបានផ្តល់ជូនឡើយ លុះត្រាតែបានបង់កំរៃអាជ្ញាប័ណ្ណ ដែលបានបញ្ជាក់ នៅក្នុងប្រកាសរួមរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ស្តីពីការបង់កំរៃអាជ្ញាប័ណ្ណ។

២- វិសាលភាពនៃអាជ្ញាប័ណ្ណ នឹងគ្របដណ្តប់ទៅលើផលិតផល ឬទំនិញ ដែលបានកែច្នៃ ផលិតនៅក្នុងរោងចក្រ/ទីកន្លែងផលិតដែលបានចែងនៅក្នុងអាជ្ញាប័ណ្ណ និងមានពាណិជ្ជ សញ្ញា/ពាណិជ្ជនាមដែលបានចុះនៅក្នុងអាជ្ញាប័ណ្ណ ព្រមទាំងមានបញ្ជាក់អំពីប្រភេទ ទំហំ រសជាតិ គំរូ ។ល ។នៅក្នុងលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណ ។

៣- ហាមធ្វើចរាចរនិងលក់ផលិតផល ឬទំនិញដែល :

- មិនបានបំពេញទៅតាមវិសាលភាពនៃស្តង់ដាមួយដូចបានចែងនៅក្នុងអាជ្ញាប័ណ្ណ ហើយ មិនមានប្រើសញ្ញាបញ្ជាក់ផលិតផល
- ប្រើសញ្ញាបញ្ជាក់ផលិតផល តែមិនអនុលោមទៅតាមការតំរូវនៃស្តង់ដា និង
- ផលិតនៅក្នុងរោងចក្រ ឬកន្លែងផលិតណាមួយដែលខុសពីរោងចក្រ ឬកន្លែងផលិត ដែល បានចុះនៅក្នុងអាជ្ញាប័ណ្ណ លើកលែងតែរោងចក្រ ឬ កន្លែងផលិតនោះបានទទួលការ អនុញ្ញាតដោយឡែកណាមួយ ។

៤- ក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណផលិតផលិតផលដូចគ្នាណាមួយ ដែលមានប្រភេទ ទំហំ រសជាតិ គំរូ ។ល ។ផ្សេងពីការចែងនៅក្នុងលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណ ហើយស្ថិតនៅក្នុង វិសាលភាពនៃស្តង់ដាដូចគ្នានោះ ប្រភេទ ទំហំ រសជាតិ គំរូ ។ល ។ទាំងនោះនៃផលិតផល ត្រូវតែអនុលោមតាមស្តង់ដាដែលបានកំណត់ និងត្រូវអនុវត្តតាមលក្ខខណ្ឌអាជ្ញាប័ណ្ណ ។

៥- អ្នកកាន់អាជ្ញាប័ណ្ណត្រូវតែផ្តល់ពត៌មានជាលាយលក្ខណ៍អក្សរភ្លាមទៅក្រសួងអំពីប្រភេទ ទំហំ រសជាតិ គំរូ ។ល ។នៃផលិតផលដែលបានយោងនៅក្នុងចំណុច ៤ ខាងលើ ។

៦- នៅពេលអាជ្ញាប័ណ្ណត្រូវបានផ្តល់ដោយយោងទៅតាមទីកន្លែងកែច្នៃ ដំណើរការផលិតកម្ម ប្រព្រឹត្តកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រសិនបើផលិតផលដូចគ្នា បិទពាណិជ្ជសញ្ញា ឬពាណិជ្ជនាមដូចគ្នាដែលបាននាំចូល ផលិតផលនាំចូលទាំងនោះមិនស្ថិតនៅក្នុងវិសាលភាព នៃអាជ្ញាប័ណ្ណទេ ។ ផលិតផលទាំងឡាយណាដែលស្ថិតនៅក្នុងវិសាលភាព នៃអាជ្ញាប័ណ្ណ

ត្រូវតែបែងចែកឱ្យច្បាស់លាស់ដាច់ពីផលិតផលនាំចូល ដោយយោងទៅតាមរបៀបមួយដែលបានបញ្ជាក់នៅក្នុងលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណ ។

៧- អ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំកម្មវិធីគ្រប់ករណីចាំបាច់ សំរាប់នាយកដ្ឋានធ្វើសវនកម្មលើប្រព័ន្ធធានាគុណភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណ និងធ្វើការត្រួតពិនិត្យ ធ្វើអធិការកិច្ច និងធ្វើការផ្ទៀងផ្ទាត់លើភាពអនុលោមទាំងអស់ទៅតាមលក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណនេះ និងទៅតាមលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណ ។

៨- ក្នុងករណីដែលការកែច្នៃ ដំណើរការផលិត ប្រព្រឹត្តកម្មនៃផលិតផល ឬទំនិញត្រូវបានជួលបន្តដោយអ្នកកាន់អាជ្ញាប័ណ្ណ អ្នកកាន់អាជ្ញាប័ណ្ណត្រូវទទួលខុសត្រូវដូចខាងក្រោម :

ក) ធានាថា អ្នកជួលបន្តបានអនុលោមទៅតាមលក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណនេះ និងទៅតាមលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណ

ខ) រៀបចំជាមួយអ្នកជួលបន្ត សំរាប់ឱ្យនាយកដ្ឋានធ្វើសវនកម្មលើប្រព័ន្ធធានាគុណភាពរបស់អ្នកជួលបន្ត និងធ្វើការត្រួតពិនិត្យ ធ្វើអធិការកិច្ច និងធ្វើការផ្ទៀងផ្ទាត់លើភាពអនុលោមទៅតាមលក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណនេះ និងទៅតាមលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណ ។

៩- អាជ្ញាប័ណ្ណ :

ក) នឹងត្រូវបានផ្តល់ឱ្យចំពោះផលិតផលដែលមានពាណិជ្ជសញ្ញា ឬពាណិជ្ជនាម

ខ) នឹងត្រូវបានផ្តល់ឱ្យចំពោះស្ថានីមួយៗ និងចំពោះរោងចក្រនីមួយៗ

គ) នឹងត្រូវមានសុពលភាពក្នុងរយៈពេលបីឆ្នាំ គិតពីថ្ងៃដែលផ្តល់ឱ្យ និង

ឃ) អាចត្រូវបានផ្តល់ឱ្យសារជាថ្មី ដោយអ្នកកាន់អាជ្ញាប័ណ្ណត្រូវធ្វើសំណើទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានសាមសិបថ្ងៃមុនថ្ងៃផុតកំណត់សុពលភាពរបស់អាជ្ញាប័ណ្ណ និងមានការបង់កំរៃអាជ្ញាប័ណ្ណ ។

១០- ក្រសួងអាចផ្តល់អាជ្ញាប័ណ្ណទុតិយតាឱ្យអ្នកកាន់អាជ្ញាប័ណ្ណ នៅពេលដែលបានបង្ហាញហេតុផលសមរម្យថា អាជ្ញាប័ណ្ណត្រូវបានខូច រហែក ឬបាត់បង់ ។

ប្រការ ៥: ការពិនិត្យអង្កេត

ការពិនិត្យអង្កេតផលិតផលលើមូលដ្ឋាននៃការគំរូរបស់ស្តង់ដាពាក់ព័ន្ធ និងប្រព័ន្ធធានាគុណភាពដែលបានបញ្ជាក់នៅក្នុងលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណ ត្រូវទទួលរ៉ាប់រងធ្វើដោយនាយកដ្ឋាន

ស្តង់ដាឧស្សាហកម្មកម្ពុជា ។ នាយកដ្ឋានត្រូវផ្តល់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណនូវលទ្ធផលនៃការពិនិត្យអង្កេតនេះ ។

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ពត៌មានទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលវិញនូវរាល់ការកែប្រែណាមួយក្នុងផលិតផល ដំណើរការផលិតកម្ម ឬប្រព័ន្ធធានាគុណភាព ដែលអាចមានឥទ្ធិពលទៅលើភាពអនុលោមនៃផលិតផល ។ ក្នុងករណីបែបនេះ អ្នកកាន់អាជ្ញាប័ណ្ណមិនអាចបញ្ចេញផលិតផលដែលមានបិទសញ្ញាបញ្ជាក់ផលិតផល ដែលជាលទ្ធផលចេញមកពីការកែប្រែទាំងនោះបានទេ លុះត្រាតែមានការយល់ព្រមពីក្រសួងជាមុនសិន ។

អ្នកកាន់អាជ្ញាប័ណ្ណត្រូវរក្សាទុកឯកសារកត់ត្រានៃការតវ៉ាទាំងអស់ ដែលទាក់ទងទៅនឹងផលិតផលដែលបានទទួលអាជ្ញាប័ណ្ណ និងត្រូវមានឯកសារនោះសំរាប់នាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា បើមានសំណូមពរ ។

ប្រការ ៦: ការព្យួរទុក និង ការដកហូតអាជ្ញាប័ណ្ណ

១- អាជ្ញាប័ណ្ណដែលអនុវត្តចំពោះផលិតផលជាក់លាក់មួយ អាចត្រូវបានព្យួរទុកក្នុងរយៈពេលមួយមិនលើសពីបីខែក្នុងមួយលើក ប្រសិនបើ :

ក) មិនបានប្រតិបត្តិតាម លក្ខខណ្ឌអាជ្ញាប័ណ្ណ

ខ) ប្រើប្រាស់អាជ្ញាប័ណ្ណ ឬសញ្ញាអនុលោមមិនបានត្រឹមត្រូវ ដោយការបោះពុម្ព ឬការផ្សព្វផ្សាយមិនបានត្រឹមត្រូវ ហើយមិនបានចាត់វិធានការដោះស្រាយ ឬកែតំរូវឱ្យបានទាន់ពេលវេលា

គ) បានប្រើសញ្ញាបញ្ជាក់ផលិតផលលើផលិតផល ឬដំណើរការផលិតកម្ម ដែលមិនអនុលោមតាមស្តង់ដាកំណត់ពាក់ព័ន្ធ

ឃ) មិនបានផ្តល់សម្ភារៈបរិក្ខាដែលប្រើសំរាប់ធ្វើអធិការកិច្ច ឬគំរូផលិតផលសំរាប់ធ្វើតេស្ត

ង) រំលោភទៅនឹងបទបញ្ញត្តិណាមួយនៃអនុក្រឹត្យលេខ ៤ ២អនក្រ.បក ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីស្តង់ដាឧស្សាហកម្មកម្ពុជា ប្រកាស ឬបទបញ្ជាពាក់ព័ន្ធ ។

២- អាជ្ញាប័ណ្ណអាចត្រូវបានដកហូតនៅពេលដែលបានរកឃើញថា អ្នកកាន់អាជ្ញាប័ណ្ណ :

ក) អនុវត្តខុសធ្ងន់ធ្ងរទៅនឹងការតំរូវនៃលក្ខខណ្ឌអាជ្ញាប័ណ្ណ

ខ) មិនបានបំពេញលក្ខខណ្ឌទាំងឡាយដែលបានតំរូវឱ្យធ្វើការកែតំរូវក្នុងពេលព្យួរទុក

គ) បានប្រព្រឹត្តកំហុសដូចគ្នាទៅនឹងកំហុសដែលនាំឱ្យមានការព្យួរទុកលើកមុន ក្នុងរយៈពេលបីឆ្នាំកន្លងមក ។

៣- អ្នកកាន់អាជ្ញាប័ណ្ណនឹងត្រូវបានទទួលដំណឹង ដប់ប្រាំថ្ងៃមុនពេលព្យួរទុក ឬដកហូតអំពីបំណង និងមូលហេតុដែលនាំឱ្យមានការព្យួរទុក ឬដកហូត

៤- នៅពេលអាជ្ញាប័ណ្ណត្រូវបានព្យួរទុក ឬដកហូត អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវបញ្ជាក់តាមរូបភាពណាមួយបង្ហាញថា ផលិតផលនោះមានអាជ្ញាប័ណ្ណទេ ហើយត្រូវតែផ្អាកភ្លាមនូវការប្រើសញ្ញាបញ្ជាក់ផលិតផលនោះ និងត្រូវ :

- ចាត់វិធានការចាំបាច់ដកសញ្ញាបញ្ជាក់ផលិតផលចេញ ឬលុបចោលចេញពីផលិតផល
- ប្រគល់អាជ្ញាប័ណ្ណមកក្រសួងវិញ ។

៥-ប្រសិនបើនៅពេលណាមានការលំបាកក្នុងការរក្សាផលិតផលឱ្យអនុលោមបានទៅតាមស្តង់ដា ឬមួយសម្ភារៈធ្វើតេស្តខូចប្រើការមិនកើត ត្រូវផ្តល់ដំណឹងទៅក្រសួងឱ្យបានដឹង ឬប្រសិនបើមានការបញ្ជាឱ្យព្យួរទុកដោយក្រសួងសំរាប់ហេតុផលណាមួយ ការដាក់សញ្ញាបញ្ជាក់ផលិតផលលើផលិតផលត្រូវតែបញ្ឈប់ ។ ការដាក់សញ្ញាបញ្ជាក់ផលិតផលអាចអនុវត្តសារជាថ្មីឡើងវិញភ្លាម នៅពេលបញ្ហាទាំងអស់ត្រូវបានដោះស្រាយ ឬនៅពេលដែលក្រសួងអនុញ្ញាតឱ្យប្រើសញ្ញាបញ្ជាក់ផលិតផលឡើងវិញ ។ ការចាប់ផ្តើមប្រើសញ្ញាបញ្ជាក់ផលិតផលសារជាថ្មីត្រូវផ្តល់ដំណឹងទៅក្រសួង ។

៦-ប្រសិនបើការផលិតផលិតផលត្រូវបានបញ្ឈប់រហូតក្នុងរយៈពេលប្រាំមួយខែត្រូវ ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួង ហើយសញ្ញាបញ្ជាក់ផលិតផលត្រូវព្យួរទុកសិន ។ នៅពេលដំណើរការផលិតឡើងវិញ ត្រូវតែមានការវាយតំលៃសារជាថ្មីដោយនាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា មុនពេលអនុម័តឱ្យប្រើសញ្ញាបញ្ជាក់ផលិតផលសារជាថ្មី ។

ប្រការ ៧: ការបិទសញ្ញាបញ្ជាក់ផលិតផល

អ្នកកាន់អាជ្ញាប័ណ្ណនីមួយៗ :

ក) ត្រូវបិទសញ្ញាបញ្ជាក់ផលិតផលលើផលិតផល ឬលើសម្ភារៈវេចខ្ចប់ផលិតផលក្នុងរបៀបមួយដែលងាយស្រួលមើលឃើញ

ខ) ត្រូវបិទបន្ថែមលេខស្តង់ដានិងលេខកូដភ្ជាប់នឹងសញ្ញាបញ្ជាក់ផលិតផល ក្នុងរបៀបមួយដែលងាយស្រួលមើលឃើញពីក្រោម ឬពីចំហៀងនៃសញ្ញាបញ្ជាក់ផលិតផលនោះ

គ) មិនត្រូវផ្ទេរការប្រើប្រាស់សញ្ញាបញ្ជាក់ផលិតផលពីផលិតផលមួយទៅផលិតផលមួយផ្សេងទៀតឡើយ ។

ប្រការ ៨: ការផ្សព្វផ្សាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ

អ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធិផ្សព្វផ្សាយថា ខ្លួនត្រូវបានទទួលសិទ្ធិប្រើសញ្ញាបញ្ជាក់ផលិតផល សំរាប់ផលិតផលទាំងឡាយណាដែលមានចុះនៅក្នុងអាជ្ញាប័ណ្ណ ។

ក្នុងគ្រប់ករណីអ្នកកាន់អាជ្ញាប័ណ្ណត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះការបោះផ្សាយ និងផ្សព្វផ្សាយពាណិជ្ជកម្មថា គ្មានការភាន់ច្រឡំកើតឡើងទេ រវាងផលិតផលមានអាជ្ញាប័ណ្ណ និង ផលិតផលគ្មានអាជ្ញាប័ណ្ណ ។

អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវពោលអះអាង ឬផ្សព្វផ្សាយពតិមាន ដែលអាចធ្វើឱ្យអ្នកទិញ ភាន់ច្រឡំជឿថា ការប្រើប្រាស់ផលិតផលបានស្ថិតនៅក្រោមការបញ្ជាក់ផលិតផល ដែលខុសពីខ្លឹមសារនៃការផ្តល់អាជ្ញាប័ណ្ណ ។ សៀវភៅណែនាំ ឬពតិមានអំពីការប្រើប្រាស់ផ្សេងៗទៀតដែលមានភ្ជាប់ជាមួយផលិតផល និងជាប់ទាក់ទិនទៅនឹងប្រព័ន្ធចេញវិញ្ញាបនប័ត្រ ត្រូវតែមានការអនុម័តពីនាយកដ្ឋានជាមុនសិន ប្រសិនបើមានការតំរូវដោយលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណនោះ ។

ប្រការ ៩: ការរក្សាការសំងាត់

នាយកដ្ឋានជាអ្នកទទួលខុសត្រូវក្នុងការធានាថា មន្ត្រីនិងភ្នាក់ងាររបស់ខ្លួនត្រូវតែរក្សាឱ្យបាននូវការសំងាត់ដែលពាក់ព័ន្ធទៅនឹងពតិមានសំងាត់ទាំងអស់ ដែលបានដឹងដោយសារលទ្ធផលនៃការទំនាក់ទំនងជាមួយអ្នកកាន់អាជ្ញាប័ណ្ណ ។

ប្រការ ១០: ភាពអនុលោម

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវ :

ក) ធានាថា ផលិតផល ឬដំណើរការផលិតកម្មដែលប្រើសញ្ញាបញ្ជាក់ផលិតផលបានអនុលោមតាមស្តង់ដាកំណត់គ្រប់ពេលវេលា

ខ) បង្កើត រក្សាទុក និងរៀបចំឯកសារប្រព័ន្ធធានាគុណភាពដែលអាចអនុវត្តបានទៅលើផលិតផល ឬ ដំណើរការផលិតកម្មដែលពាក់ព័ន្ធ

គ) ថែរក្សាឯកសារកត់ត្រាពេញលេញ និងបង្កើតថ្មីលើប្រព័ន្ធត្រួតពិនិត្យ ក្នុងគោលបំណងធ្វើឱ្យការត្រួតពិនិត្យនេះមានស្ថេរភាពរហូត

ឃ) ផ្តល់ភាពងាយស្រួលដល់ការធ្វើអធិការកិច្ចតាមតំរូវការរបស់មន្ត្រីមានសមត្ថកិច្ចនូវឯកសារនិងការកត់ត្រាយោងទាំងឡាយនៅក្នុងចំណុច ខ និង គ ខាងលើនេះ

ង) អនុញ្ញាតឱ្យយកនូវឯកសារ ឬការកត់ត្រាចេញពីកន្លែងរបស់ខ្លួនទៅក្រសួង សំរាប់ការពិនិត្យឱ្យបានម៉ត់ចត់ ។

២- ការរៀបចំទូទៅសំរាប់ការធ្វើតេស្ត

ក) ការធ្វើតេស្ត និងការធ្វើអធិការកិច្ចដែលបានបញ្ជាក់នៅក្នុងផែនការគុណភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវតែធ្វើឡើងដោយអ្នកកាន់អាជ្ញាប័ណ្ណ ដោយប្រើប្រាស់ឧបករណ៍ធ្វើតេស្តផ្ទាល់ខ្លួនក៏បាន និង/ឬ តាមរយៈនាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជាក៏បាន និង/ឬ តាមរយៈមន្ទីរពិសោធន៍ផ្សេងទៀតដែលបានទទួលស្គាល់ជាផ្លូវការក៏បាន ។

ខ) ប្រសិនបើក្រសួងបង្ហាញពីបំណងនៃការផ្លាស់ប្តូរ ឬការប្រែប្រួលក្នុងរបៀបណាមួយសំរាប់ការធ្វើតេស្ត និងសំរាប់ការត្រួតពិនិត្យគុណភាពផលិតផលដែលជាការចាំបាច់ ក្រសួងត្រូវផ្តល់ដំណឹងយ៉ាងតិចបីខែមុនការផ្លាស់ប្តូរ ឬការប្រែប្រួលនេះ ។

គ) ការផ្លាស់ប្តូរ ឬការប្រែប្រួលនេះ ត្រូវតែជាភារកិច្ចរបស់អ្នកកាន់អាជ្ញាប័ណ្ណរហូតដល់ផុតសុពលភាពដែលបានកំណត់ យោងទៅតាមលក្ខខណ្ឌ ២ ខ ខាងលើ ដែលបានបញ្ជាក់ថាអ្នកកាន់អាជ្ញាប័ណ្ណត្រូវតែទទួលយកនូវការផ្លាស់ប្តូរ ឬការប្រែប្រួលក្នុងការរៀបចំសំរាប់ការធ្វើតេស្ត និងការត្រួតពិនិត្យគុណភាពផលិតផលមុនរយៈពេលផុតកំណត់ខាងលើ ។

ឃ) មន្ត្រីមានសមត្ថកិច្ចរបស់នាយកដ្ឋាន អាចយកគំរូផលិតផលនៅតាមទីផ្សារ ឬទីកន្លែងផលិតរបស់អ្នកកាន់អាជ្ញាប័ណ្ណសំរាប់ការធ្វើតេស្ត និង/ឬការធ្វើអធិការកិច្ច ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវតែបង់ថ្លៃចំណាយទាំងអស់លើការយកគំរូផលិតផលខាងលើនេះ ។

ង) អ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំផលិតផលជាឡូត៍ ហើយសម្ភារៈផ្សេងៗ ឬសម្ភារៈវេចខ្ចប់ដែលបានប្រើប្រាស់ប្រសិនបើមាន ត្រូវតែបានគូសជាសញ្ញាតាមរបៀបមួយដែលអាចទទួលយកបានដោយនាយកដ្ឋាន ដើម្បីឱ្យគំរូផលិតផលនីមួយៗអាចតាមដានបានទៅលើឡូត៍របស់វា ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវតែផ្តល់ឱ្យនាយកដ្ឋាននូវនិយមន័យនៃឡូត៍ របៀបលំអិតនៃការធ្វើអត្តសញ្ញាណរបស់ឡូត៍ដែលបានកត់ចំណាំប្រព័ន្ធលេខកូដនៃអត្តសញ្ញាណរបស់ឡូត៍ជាដើម ។

៣- ឯកសារកត់ត្រាការធ្វើតេស្ត

ក) អ្នកកាន់អាជ្ញាប័ណ្ណត្រូវរក្សាទុកឯកសារកត់ត្រាគុណភាពដូចដែលបានតំរូវ ទៅតាមការតំរូវនៃប្រព័ន្ធធានាគុណភាព ដើម្បីបំពេញតាមការតំរូវរបស់នាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា ដែលផលិតកម្ម ឬដំណើរការផលិតកម្មត្រូវបាននិងកំពុងតែត្រូវបានថែរក្សាទុក

យ៉ាងត្រឹមត្រូវ ។ ឯកសារកត់ត្រាទាំងនោះ ត្រូវរៀបចំផ្ញើទៅនាយកដ្ឋានតាមសំណើសំរាប់ការធ្វើអធិការកិច្ច ។

ខ) ឯកសារកត់ត្រាដោយឡែក ត្រូវតែរក្សាទុកដើម្បីផ្តល់ពត៌មានដែលទាក់ទងទៅនឹងការមិនទទួលស្គាល់ផលិតផលនៃឡូត៍ទាំងឡាយណាដែលមិនអនុលោមតាមស្តង់ដា និងវិធីបញ្ចេញកាកសំណល់ និង/ឬ ការប្រើប្រាស់ឡើងវិញនូវកាកសំណល់របស់ផលិតផលទាំងនោះ ។

ប្រការ ១១: ការជំនួស

រាល់ពេលមានការតវ៉ាត្រឹមត្រូវណាមួយលើផលិតផលដែលខូច ផលិតផលនោះត្រូវតែបានជំនួសដោយផលិតផលថ្មី ហើយអ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវគិតថ្លៃលើផលិតផលថ្មីនោះឡើយ ។

សិទ្ធិអំណាចចុងក្រោយក្នុងការសំរេចភាពត្រឹមត្រូវនៃការតវ៉ា ត្រូវធ្វើឡើងដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ១២: ការលុបចោលអាជ្ញាប័ណ្ណ

អាជ្ញាប័ណ្ណមួយត្រូវបានលុបចោលនៅពេលដែល

១- អ្នកកាន់អាជ្ញាប័ណ្ណបញ្ឈប់ដំណើរការផលិតកម្មរបស់ខ្លួន

២- អ្នកកាន់អាជ្ញាប័ណ្ណស្នើសុំឈប់បិទសញ្ញាបញ្ជាក់ផលិតផលនៅលើផលិតផលរបស់ខ្លួន

៣- មានសេចក្តីជូនដំណឹង ឬប្រកាសដែលកំណត់អំពីស្តង់ដាថ្មីមួយ ការកែប្រែ ឬការដកហូតស្តង់ដា ដែលទាក់ទិនទៅនឹងប្រភេទផលិតផលទាំងនោះចូលជាធរមាន ។

ប្រការ ១៣ : នៅពេលដែលអ្នកកាន់អាជ្ញាប័ណ្ណមានបំណងឈប់ប្រើប្រាស់សញ្ញាបញ្ជាក់ផលិតផល ហើយជាមួយគ្នានោះដែរ មានបំណងបោះបង់ចោលអាជ្ញាប័ណ្ណរបស់ខ្លួន អ្នកកាន់អាជ្ញាប័ណ្ណត្រូវសរសេរជាលាយលក្ខណ៍អក្សរជូនដំណឹងបញ្ជាក់ពីមូលហេតុទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ គ្មានការសងវិញទាំងស្រុង ឬចំណែកណាមួយនៃកំរៃអាជ្ញាប័ណ្ណដែលបានបង់នោះឡើយ។ ការបោះបង់ចោលអាជ្ញាប័ណ្ណត្រូវបានចាត់ទុកថា ជាការបញ្ឈប់ការប្រើប្រាស់សញ្ញាបញ្ជាក់ផលិតផល ចាប់ពីថ្ងៃចុងក្រោយបង្អស់នៃខែដែលបានទទួលសេចក្តីសំរេចជាផ្លូវការរបស់ក្រសួង ហើយអ្នកកាន់អាជ្ញាប័ណ្ណត្រូវបានតំរូវឱ្យឈប់ប្រើតទៅទៀតនូវសញ្ញាបញ្ជាក់ផលិតផលនៅលើ ផលិតផលទាំងនោះ ។

ប្រការ ១៤ : ក្នុងករណីមានការកំណត់ស្តង់ដាថ្មីមួយ ឬមានការកែប្រែស្តង់ដា អ្នកកាន់អាជ្ញាប័ណ្ណដែលមានបំណងអនុលោមតាមស្តង់ដាថ្មី ឬស្តង់ដាដែលមានការកែប្រែនោះ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណឱ្យបានមុនកាលបរិច្ឆេទចូលជាធរមាននៃស្តង់ដាថ្មី ឬស្តង់ដាដែលបានកែប្រែនោះ ។ បន្ទាប់ពីបានដាក់ពាក្យស្នើសុំរួច អ្នកកាន់អាជ្ញាប័ណ្ណអាចបន្តដំណើរការរបស់ខ្លួនទៅក្រោមអាជ្ញាប័ណ្ណនិងស្តង់ដាចាស់ក្នុងរយៈពេលមួយដែលបានកំណត់ដោយនាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា គឺមិនលើសពីមួយឆ្នាំគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃស្តង់ដាថ្មី ឬស្តង់ដាដែលបានកែប្រែ ។

ប្រការ ១៥ : ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ១៦ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ស៊ុយ សែម

ចម្លងជូន:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  (ដើម្បីគោរពជូនជ្រាប)
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងព័ត៌មាន
- គ្រប់មន្ទីរឧស្សាហកម្មរ៉ែនិងថាមពលខេត្ត-ក្រុង
  (ដើម្បីជ្រាប)
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យស្នើសុំវិញ្ញាបនបត្រ និងអាជ្ញាប័ណ្ណប្រើសញ្ញាបញ្ជាក់ផលិតផល

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................អាយុ..........ឆ្នាំ សញ្ជាតិ..................ឋានៈ....................................

ក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម...

មានអាសយដ្ឋានៈ ផ្ទះលេខ...............................ផ្លូវ/វិថី..............................ភូមិ/ក្រុម..

ឃុំ/សង្កាត់ ....ស្រុក / ខណ្ឌ ....ខេត្ត / ក្រុង..

ទូរស័ព្ទលេខ.. អ៊ីម៉ែល / Email: ....

សូមគោរពជូន

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

កម្មវត្ថុ: សំណើសុំវិញ្ញាបនប័ត្រ និង អាជ្ញាប័ណ្ណប្រើសញ្ញាស្តង់ដា : ☐ចុះបញ្ជីផលិតផល ☐បញ្ជាក់ផលិតផល ☐បញ្ជាក់សុវត្ថិភាព

ដែលប្រើពាណិជ្ជសញ្ញា. ....

ផលិតចេញពីក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម ....

អាសយដ្ឋានផលិតកម្ម .... ផ្លូវ/វិថី.................. ក្រុម/ភូមិ ....

ឃុំ/សង្កាត់ .... ស្រុក/ខណ្ឌ ....ខេត្ត/ក្រុង ....

ទូរស័ព្ទលេខ... អ៊ីម៉ែល / Email: ....

សេចក្តីអធិប្បាយអំពីផលិតផល (១)	ស្តង់ដាពាក់ព័ន្ធ (២)	គោលការណ៍ និងលក្ខខណ្ឌពាក់ព័ន្ធ (៣)
....	....	១- អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីស្តង់ដាឧស្សាហកម្មកម្ពុជា ២- CS 002:2001 (គោលការណ៍ទូទៅនៃប្រព័ន្ធចេញវិញ្ញាបនប័ត្របញ្ជាក់ផលិតផលដោយភាគីទី៣) ៣- ប្រកាសស្តីពីលក្ខខណ្ឌទូទៅនៃការផ្តល់អាជ្ញាប័ណ្ណសំរាប់ប្រើសញ្ញាបញ្ជាក់ផលិតផល ៤- កិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ ៥- លក្ខខណ្ឌជាក់លាក់

ជូនភ្ជាប់មកជាមួយនូវ:

(១) ប្រកាស/សេចក្តីសំរេច អនុញ្ញាតបើកក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល (ថតចម្លង)

(២) គំនូសបំព្រួញខ្សែសង្វាក់ផលិតកម្ម

(៣) បញ្ជីរាយឈ្មោះ គ្រឿងចក្រ-ម៉ាស៊ីន និងឧបករណ៍ប្រើប្រាស់ក្នុងការផលិត

(៤) បញ្ជីរាយឈ្មោះវត្ថុធាតុដើម ដែលប្រើប្រាស់ក្នុងការផលិត

(៥) គំរូស្លាកសញ្ញាដែលមានបំណងប្រើប្រាស់សញ្ញាស្តង់ដា

(៦) វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជសញ្ញានៃផលិតផល (ប្រសិនបើមាន)

(៧) វិញ្ញាបនប័ត្រពី GS1 CAMBODIA (ប្រសិនបើមាន)

(៨) ឯកសារដែលទាក់ទងទៅនឹង (១) (២) (៣) ឬ (៤) ឬឯកសារផ្សេងៗទៀត ។

***ខ្ញុំបាទ/នាងខ្ញុំ សូមប្រកាសថា*:**

១- នឹងបង់កំរៃអាជ្ញាប័ណ្ណ និងកំរៃផ្សេងៗទៀតដែលទាក់ទងនឹងការដាក់ពាក្យស្នើសុំនេះ

២- នឹងសុខចិត្តទទួលយល់ព្រមតាមគោលការណ៍ និងលក្ខខណ្ឌពាក់ព័ន្ធដែលមានចែងនៅក្នុងជំពូកទី៣ នៃតារាងខាងលើ ។

សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ ។

.... ថ្ងៃទី .... ខែ ....ឆ្នាំ២០០.......

ប្រធានក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម

ហត្ថលេខា

ឈ្មោះ ....

បញ្ជីរាយឈ្មោះវត្ថុធាតុដើម

សំរាប់ផលិត...

របស់ ក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម : ....

អាសយដ្ឋាន :...

ល.រ	ឈ្មោះវត្ថុធាតុដើម	មុខសញ្ញាប្រើប្រាស់	បរិមាណដែលប្រើគិតជា% នៃផលិតផលសំរេច	ផ្សេងៗ
១				
២				
៣				
៤				
៥				
៦				
៧				
៨				
៩				
១០				
១១				
១២				
១៣				
១៤				
១៥				
១៦				
១៧				

.... ថ្ងៃទី..........ខែ...............ឆ្នាំ.២០០

ប្រធានក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម

ហត្ថលេខា

គំនូសបំព្រួញនៃខ្សែសង្វាក់ផលិតកម្ម

ក្នុងការផលិត ....

របស់ ក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម :...

អាសយដ្ឋាន:...

.... ថ្ងៃទី.........ខែ.............ឆ្នាំ ២០០

ប្រធានក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម

ហត្ថលេខា

(អាចគូរលើក្រដាសផ្សេង ប្រសិនបើចាំបាច់ ប៉ុន្តែត្រូវតែមានការទទួលស្គាល់ពីប្រធានក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម)

បញ្ជីរាយឈ្មោះ គ្រឿងចក្រ-ម៉ាស៊ីន និងឧបករណ៍ប្រើប្រាស់ក្នុងការផលិត

សំរាប់ផលិត...

របស់ ក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម : ....

អាសយដ្ឋាន :...

ល.រ	ម៉ាស៊ីន និងឧបករណ៍ប្រើប្រាស់ក្នុងការផលិត ផលិតផល	ថ្ងៃតម្លើង ម៉ាស៊ីន-ឧបករណ៍	ថ្ងៃធ្វើការផ្ទៀងផ្ទាត់ ម៉ាស៊ីន-ឧបករណ៍	ផ្សេងៗ
១				
២				
៣				
៤				
៥				
៦				
៧				
៨				
៩				
១០				
១១				
១២				
១៣				
១៤				
១៥				
១៦				

.... ថ្ងៃទី..........ខែ..............ឆ្នាំ ២០០

ប្រធានក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម

ហត្ថលេខា

ឧបសម្ព័ន្ធ ២

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
Ministry of Industry, Mines and Energy
នាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា
Department of Industrial Standards of Cambodia

លេខ:
Number

ថ្ងៃចេញ:
Date of Issue

វិញ្ញាបនប័ត្រផលិតផល
Product Certificate

នាយកដ្ឋានផ្តល់វិញ្ញាបនប័ត្រផលិតផលនេះជូន
The Department hereby grants this Product Certificate to

ក្រុមហ៊ុន (Company) ....

អាសយដ្ឋាន (Address)..

ដើម្បីផលិត
to produce

ផលិតផល (Product)..

ម៉ាក (Trade Mark) ....

បានអនុលោមតាមស្តង់ដាកម្ពុជា (Complying with Cambodian Standard)
CS 00X : 2005

ប្រធាននាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា
Director of Department of Industrial Standards of Cambodia

វិញ្ញាបនប័ត្រនេះត្រូវបានផ្តល់ចំពោះក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម ដែលបានអនុវត្តទៅតាមការតំរូវនិងលក្ខខណ្ឌនៃប្រព័ន្ធចេញវិញ្ញាបនប័ត្រផលិតផល
This certificate is awarded subject to the Company's compliance with the prescribed requirements and conditions of the Product Certification Scheme

ឧបសម្ព័ន្ធ ៣

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
Ministry of Industry, Mines and Energy

អាជ្ញាប័ណ្ណ

សំរាប់ប្រើសញ្ញាបញ្ជាក់ផលិតផល
License for the Use of Product Certification Mark

អាជ្ញាបណ្ណលេខ License No.: .... ថ្ងៃចេញ Date of Issue: ....

យោងវិញ្ញាបនប័ត្រលេខ Referred Certificate Number: .... ថ្ងៃចេញ Date of Issue: ....

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
Ministry of Industry, Mines and Energy

ផ្តល់ជូន Granted to:......................................ចាប់ពីពេលនេះទៅហៅថា **អ្នកកាន់អាជ្ញាប័ណ្ណ** Thereby called **Licensee**

អាសយដ្ឋានផលិតកម្ម Address: ....

ចាប់ពីពេលនេះ អ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធិប្រើសញ្ញាស្តង់ដារបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ដែលបានបង្ហាញនៅក្នុងជួរឈរទី១ សំរាប់ផលិតផលដែលមានឈ្មោះនៅក្នុងជួរឈរទី២ ដោយបានផលិតអនុលោមតាមស្តង់ដាដែលមាននៅក្នុងជួរឈរទី៤ នៃតារាងខាងក្រោម ។

ផលិតផលដែលទទួលបានអាជ្ញាប័ណ្ណ Products for which the license is granted		ប្រភេទ ឬ លក្ខណៈសំគាល់ផ្សេងៗទៀតរបស់ផលិតផល Type or other description of products (3)	ស្តង់ដាយោង Referred Standard(s) (4)	លក្ខខណ្ឌកំណត់ Specific conditions (5)
សញ្ញាស្តង់ដា ISC ISC Standard Mark (1)	ផលិតផល , ម៉ាកផលិតផល Product , Trade Mark (2)			
CS-00X:2005 00X/05				១-អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៩ខែឧសភា ឆ្នាំ ២០០១ ស្តីពីស្តង់ដាឧស្សាហកម្មកម្ពុជា ២-ប្រកាសស្តីពីលក្ខខណ្ឌទូទៅនៃការផ្តល់អាជ្ញាប័ណ្ណសំរាប់ប្រើសញ្ញាបញ្ជាក់ផលិតផល ៣- កិច្ចព្រមព្រៀងនៃការប្រើសញ្ញា ៤- លក្ខខណ្ឌជាក់លាក់

ថ្ងៃផុតកំណត់ Date of Expiry : ....

រដ្ឋមន្ត្រី
Minister

អាជ្ញាប័ណ្ណនេះត្រូវបានផ្តល់ចំពោះអ្នកកាន់អាជ្ញាប័ណ្ណដែលបានអនុវត្តទៅតាមការតំរូវនៃប្រព័ន្ធគុណភាពនិងលក្ខខណ្ឌដែលបានកំណត់
This License is awarded subject to the Licensee's compliance with the quality system requirements, terms and conditions

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ០០៥ ឧរ៥-ក្រស.សលា។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៥

សេចក្តីណែនាំអនុវត្ត

ស្តីពី

ការគ្រប់គ្រង និង បែបបទអនុញ្ញាតច្បាប់
ឧស្សាហកម្មតូច-មធ្យម និង សិប្បកម្មនៅរាជធានីភ្នំពេញ

ដើម្បីអនុវត្តអោយបានជោគជ័យនូវ " យុទ្ធសាស្ត្រចតុកោណ "និងការណែនាំដ៏ម៉ឺងម៉ាត់របស់ប្រមុខរាជរដ្ឋាភិបាលនីតិកាលទី៣នៃរដ្ឋសភា ដែលក្នុងនោះការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ជាមុំអាទិភាពដ៏សំខាន់មួយក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងជំរុញការអនុវត្តលិខិតលេខ ៨៥៩ សជណ ចុះថ្ងៃ ទី០១ ខែ មិថុនា ឆ្នាំ ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលសូមធ្វើការណែនាំដូចខាងក្រោម :

I.ការគ្រប់គ្រង

ការសុំអនុញ្ញាតបើក ឬ បន្តដំណើរការផលិតកម្ម ប្តូរទីតាំង ផ្ទេរសិទ្ធគ្រប់គ្រង បន្ថែមមុខផលិតផល ពង្រីកមូលដ្ឋាន លើប្រភេទផលិតកម្ម-អាជីវកម្មឧស្សាហកម្មតូច-មធ្យម និងសិប្បកម្ម ក្នុងរាជធានី ភ្នំពេញទាំងអស់ ត្រូវអនុវត្ត តាមការដាក់ពាក្យសុំនៅច្រកចេញចូលតែមួយ ស្ថិតនៅក្នុងមជ្ឈមណ្ឌលពិព័រណ៍ផលិតផលក្នុងស្រុក ផ្លូវជាតិលេខ២ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ (អតីតរោងចក្រស្បែក ចាក់អង្រែ) និងមកទទួលយកប្រកាសអនុញ្ញាតនៅច្រកចេញ-ចូលនេះវិញក្នុងរយៈ ពេល បួនថ្ងៃ (៤ថ្ងៃ) នៃថ្ងៃធ្វើការ ក្រោយពី បានដាក់ពាក្យតាមច្រកចេញ-ចូលរួចហើយ ។

II.អំពីបែបបទសុំច្បាប់អនុញ្ញាត

សំណុំលិខិតសុំបើក ឬ បន្តដំណើរការមូលដ្ឋានឧស្សាហកម្មតូច-មធ្យម ឬសិប្បកម្ម ឬប្តូរទីតាំង ឬផ្ទេរសិទ្ធ ឬពង្រីក ឬបន្ថែមមុខផលិតផល ត្រូវប្រើប្រាស់ពាក្យសុំ (FORMS) ដែលចេញដោយ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ក./ ទំរង់បែបបទនៃការសុំបើកឧស្សាហកម្មតូច-មធ្យម ឬ សិប្បកម្ម :

ឯកសារដែលត្រូវបំពេញក្នុងការសុំអនុញ្ញាតច្បាប់បើកដំណើរការឧស្សាហកម្មតូច-មធ្យមឬសិប្បកម្មមាន:

- ពាក្យសុំបើកដំណើរការមូលដ្ឋានផលិតកម្ម មានបិទតែមប្រើយតំលៃ ៥០០៛ (ប្រាំរយរៀល) និងបិទរូបថត ៤ x ៦ ចំនួន ០១ សន្លឹក
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លង ឬឯកសារដែលមានតំលៃស្មើ
- តារាងអង្កេត
- បញ្ជីភាគហ៊ុន (បើមាន))
- គំនូសតាងបង្ហាញទីតាំង-ខ្សែសង្វាក់ផលិតកម្ម (គូដោយមន្ត្រីជំនាញដែលចុះពិនិត្យ)

ខ- ទំរង់បែបបទនៃការសុំបន្ត ដំណើរការផលិតកម្ម :

ឯកសារដែលត្រូវបំពេញក្នុងការសុំបន្តអនុញ្ញាតច្បាប់ រួមមាន :

- ពាក្យសុំបន្តដំណើរការផលិតកម្ម ត្រូវបិទតែមប្រើយ៍តំលៃ ៥០០៛ (ប្រាំរយរៀល)
- លិខិតវាយតម្លៃសកម្មភាពរបស់មូលដ្ឋានផលិតកម្មដោយមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលក្រុងភ្នំពេញ
- ប្រកាស ឬលិខិតអនុញ្ញាតបើក ឬ បន្តដំណើរការផលិតកម្ម(ច្បាប់ដើម)

គ/ ទំរង់បែបបទនៃការសុំប្តូរទីតាំងមូលដ្ឋានផលិតកម្ម:

ឯកសារដែលត្រូវបំពេញ ក្នុងការសុំផ្លាស់ប្តូរទីតាំងមូលដ្ឋានផលិតកម្មមាន:

- ពាក្យសុំផ្លាស់ប្តូរទីតាំងមូលដ្ឋានផលិតកម្ម មានបិទតែមប្រើយ៍ ៥០០៛ (ប្រាំរយរៀល)
- តារាងអង្កេត
- លិខិតវាយតម្លៃសកម្មភាពរបស់មូលដ្ឋានផលិតកម្មដោយមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ក្រុងភ្នំពេញ - ប្រកាស ឬលិខិតអនុញ្ញាតបើក ឬ បន្តដំណើរការផលិតកម្ម(ច្បាប់ដើម)

ឃ / ទំរង់បែបបទនៃការសុំផ្លាស់ប្តូរសមាសភាពគ្រប់គ្រង :

ឯកសារដែលត្រូវបំពេញក្នុងការសុំផ្លាស់ប្តូរប្រធានគ្រប់គ្រងថ្មីមាន :

- ពាក្យសុំផ្លាស់ប្តូរប្រធានថ្មីដោយមានបិទតែមប្រើយ៍ ៥០០៛ (ប្រាំរយរៀល) និងរូបថតប្រធានថ្មីទំហំ៤ x ៦
- លិខិតផ្ទេរសិទ្ធគ្រប់គ្រងមូលដ្ឋានផលិតកម្ម ដោយបញ្ជាក់ពីរដ្ឋបាលសង្កាត់
- អត្តសញ្ញាណប័ណ្ណថតចម្លង ឬ ឯកសារដែលមានតំលៃស្មើ របស់អ្នកផ្ទេរសិទ្ធិ និងអ្នកទទួលសិទ្ធិ
- ប្រកាស ឬលិខិតអនុញ្ញាតបើក ឬ បន្តដំណើរការផលិតកម្ម(ច្បាប់ដើម)

ង / ទំរង់បែបបទនៃការសុំពង្រីកមូលដ្ឋានផលិតកម្ម ឬ បន្ថែមមុខផលិតផល :

ឯកសារដែលត្រូវបំពេញរួមមាន:

- ពាក្យសុំពង្រីក ឬ បន្ថែមផលិតផល ដោយបិទតែមប្រិយ៍ ៥០០៛ (ប្រាំរយរៀល)
- តារាងអង្កេត
- លិខិតវាយតម្លៃសកម្មភាពរបស់មូលដ្ឋាន ដោយមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលក្រុងភ្នំពេញ
- ប្រកាស ឬលិខិតអនុញ្ញាតបើក ឬ បន្តដំណើរការផលិតកម្ម (ច្បាប់ដើម)

III. អំពីសិទ្ធិសម្រេច និងការកំណត់ពេលវេលា :

- សំណុំឯកសារសុំបើកមូលដ្ឋានផលិតកម្ម ត្រូវមានការឯកភាពពីរដ្ឋបាលសង្កាត់លើការបោះទីតាំង មុននឹងដាក់ចូលតាមច្រកចេញ-ចូលតែមួយ ហើយត្រូវបានថតចម្លងជាបីច្បាប់ដើម្បីដាក់ជូនស្ថាប័នពាក់ព័ន្ធរៀបចំ លិខិតបញ្ជាក់ឯកភាព :

១. មន្ទីរបរិស្ថានក្រុងភ្នំពេញលើស្ថានភាពបរិស្ថានជុំវិញមូលដ្ឋាន

២. មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលក្រុងភ្នំពេញលើសកម្មភាពផលិតកម្ម

៣. សាលាខ័ណ្ឌ និងសាលាក្រុងភ្នំពេញ លើការបោះទីតាំង

រួចបញ្ជូនមកច្រកចេញ-ចូលតែមួយដើម្បីដាក់ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលចេញប្រកាសជូន ។

- សំណុំឯកសារសុំប្តូរទីតាំង ត្រូវឆ្លងរដ្ឋបាលសង្កាត់ រួចដាក់ពាក្យមកច្រកចេញ-ចូលតែមួយ ។ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល មន្ទីរបរិស្ថានក្រុងភ្នំពេញ និងសាលាក្រុងភ្នំពេញបញ្ជាក់ឯកភាពលើពាក្យ សុំ រួចបញ្ជូនមកច្រកចេញ-ចូលតែមួយដើម្បីដាក់ជូនក្រសួង ធ្វើការសម្រេច ។

- សំណុំឯកសារសុំប្តូរសមាសភាពគ្រប់គ្រងមូលដ្ឋានផលិតកម្ម ត្រូវឆ្លងរដ្ឋបាលសង្កាត់ រួចដាក់ពាក្យមកច្រកចេញ-ចូលតែមួយ ។ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលក្រុងភ្នំពេញ បញ្ជាក់ឯកភាពលើពាក្យសុំ រួចបញ្ជូនមកច្រកចេញ-ចូលតែមួយដើម្បីដាក់ជូនក្រសួងធ្វើការសម្រេច ។

- សំណុំឯកសារសុំបន្តដំណើរការផលិតកម្ម ឬ បន្ថែមមុខផលិតផល ឬ ប្តូរខ្សែសង្វាក់ផលិតកម្ម ត្រូវដាក់ចូលតាមច្រកចេញ-ចូលតែមួយ ។ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលក្រុងភ្នំពេញ បញ្ជាក់ឯកភាពលើសកម្មភាពផលិតកម្ម រួចបញ្ជូនមកច្រកចេញ-ចូលតែមួយដើម្បីដាក់ជូនក្រសួងធ្វើការសម្រេច ។

- ក្នុងករណីដែល រដ្ឋបាលសង្កាត់ ឬ សាលាខ័ណ្ឌ ឬ មន្ទីរបរិស្ថាន ឬ មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលក្រុងភ្នំពេញ ឬ សាលាក្រុងភ្នំពេញមិនឯកភាពដោយមូលហេតុណាមួយ ត្រូវធ្វើកំណត់បង្ហាញដោយ ឡែកមួយ ដោយបញ្ជាក់អំពីមូលហេតុ អោយបានច្បាស់លាស់ និង ភ្ជាប់មកជាមួយនឹងសំណុំឯកសាររបស់មូលដ្ឋាននោះមកច្រកចេញ-ចូលតែមួយ ដើម្បីដាក់ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលពិនិត្យសម្រេចជាគោលការណ៍ ។

- មូលដ្ឋានផលិតកម្មដែលបិទទ្វារបណ្តោះអាសន្ន (រយៈពេល៦ខែឡើងទៅ) ឬ បិទជាស្ថាពរ មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលក្រុងភ្នំពេញ ត្រូវធ្វើពាក្យជូនដំណឹងមកច្រកចេញ-ចូលតែមួយ ដើម្បីរាយការណ៍ជូន ក្រសួង ។

- រាល់សំណុំឯកសារសុំបើក ដែលឆ្លងតាមរយៈសាលាខ័ណ្ឌ និងសាលាក្រុងភ្នំពេញ មិនត្រូវទុកអូសបន្លាយ អោយលើសពីបីថ្ងៃ (៣ថ្ងៃ) នៃថ្ងៃធ្វើការ ចាប់តាំងពីថ្ងៃទទួលពាក្យសុំ ។
- រាល់សំណុំឯកសារសុំបើកដែលឆ្លងតាមរយៈមន្ទីរបរិស្ថានក្រុងភ្នំពេញ មិនត្រូវទុកអូសបន្លាយអោយលើសពីបីថ្ងៃ (៣ថ្ងៃ) នៃថ្ងៃធ្វើការ ចាប់តាំងពីថ្ងៃទទួលពាក្យសុំ ។
- រាល់សំណុំឯកសារសុំបើក ឬ បន្តដំណើរការផលិតកម្ម ប្តូរទីតាំង ប្តូរខ្សែសង្វាក់ផលិតកម្ម ប្តូរសមាសភាពគ្រប់គ្រង ដែលឆ្លងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលក្រុងភ្នំពេញ មិនត្រូវទុកអូសបន្លាយអោយលើសពីបីថ្ងៃ (៣ថ្ងៃ) នៃថ្ងៃធ្វើការចាប់តាំងពីថ្ងៃទទួលពាក្យសុំ ។
- ក្នុងករណីខកខានមិនបានឆ្លើយតបតាមកាលបរិច្ឆេទដែលបានកំណត់ ត្រូវបានចាត់ទុកថាបានផ្តល់ការឯកភាពជាស្ថាពរ ហើយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នឹងចេញប្រកាសជូនអតិថិជនតាមពេលវេលាដែលបានកំណត់។ ចំពោះឯកសារដែលយឺតយ៉ាវ ត្រូវបញ្ជូនមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលជាក្រោយដើម្បីតម្កល់ទុក ។

IV. អំពីការបង់ថវិកាលើសេវាកម្ម :

ឧស្សាហករ-សិប្បករត្រូវបង់ថវិកាលើការចេញលិខិតអនុញ្ញាតបើកដំណើរការផលិតកម្មក្នុងមួយមូលដ្ឋានរយៈពេល៣ឆ្នាំ(គិតជាប្រាក់រៀលមានតម្លៃស្មើមួយរយប៉ែតសិបដុល្លាសហរដ្ឋអាមេរិក)ដែលមានដូចតទៅ :
- សម្រាប់សេវាកម្មក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មន្ទីរក្រោមឱវាទ និងសម្រាប់មូលនិធិទ្រទ្រង់ច្រកចេញ-ចូលតែមួយ និងអភិវឌ្ឍន៍វិស័យឧស្សាហកម្មតូច-សិប្បកម្ម គិតជាប្រាក់រៀលមានតម្លៃស្មើប៉ែតសិបដុល្លាសហរដ្ឋអាមេរិក
- សម្រាប់សេវាកម្មក្រសួងបរិស្ថានគិតជាប្រាក់រៀលមានតម្លៃស្មើសាមសិបដុល្លាសហរដ្ឋអាមេរិក
- សម្រាប់សេវាកម្មសាលាខ័ណ្ឌនិងសាលាក្រុងភ្នំពេញ គិតជាប្រាក់រៀលមានតម្លៃស្មើសាមសិបដុល្លាសហរដ្ឋអាមេរិក
- សម្រាប់បង់ចូលថវិការដ្ឋគិតជាប្រាក់រៀលមានតម្លៃស្មើសែសិបដុល្លាសហរដ្ឋអាមេរិក

ឧស្សាហករ-សិប្បករត្រូវបង់ថវិកាលើការចេញប្រកាសអនុញ្ញាតបន្តដំណើរការផលិតកម្ម ក្នុងមួយមូលដ្ឋានរយៈពេល៣ឆ្នាំ (គិតជាប្រាក់រៀលសរុបមានតម្លៃស្មើមួយរយដុល្លាសហរដ្ឋអាមេរិក) ដែលមានដូចតទៅ :
- សម្រាប់សេវាកម្មក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មន្ទីរក្រោមឱវាទ និងសម្រាប់មូលនិធិទ្រទ្រង់ច្រកចេញ-ចូលតែមួយ និងអភិវឌ្ឍន៍វិស័យឧស្សាហកម្មតូច-សិប្បកម្ម គិតជាប្រាក់រៀលមានតម្លៃស្មើចិតសិបដុល្លាសហរដ្ឋអាមេរិក
- សម្រាប់បង់ចូលថវិការដ្ឋគិតជាប្រាក់រៀលមានតម្លៃស្មើសាមសិបដុល្លាសហរដ្ឋអាមេរិក

V. អំពីសិទ្ធិរបស់ផលិតករ :

ក្នុងដំណើរការសុំច្បាប់អនុញ្ញាត ប្រសិនបើផលិតករពុំឯកភាពនឹងការសម្រេចចិត្តរបស់រដ្ឋបាលសង្កាត់ ឬ សមត្ថកិច្ចណាមួយខាងលើ ផលិតករនោះអាចធ្វើការតវ៉ាមកគណៈកម្មការច្រកចេញចូលតែមួយ ដើម្បីធ្វើការ សម្របសម្រួល ឬ បញ្ជូនមកក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពលធ្វើការដោះស្រាយ ។

VI. <u>អំពីភារៈកិច្ចរបស់មន្ត្រីច្រកចេញ-ចូលតែមួយ :</u>

មន្ត្រីដែលជាសមាជិកនៃច្រកចេញចូលតែមួយ លើកលែងតែតំណាងសមាគមឧស្សាហកម្មតូចនិងមធ្យម (SME) ដែលជាអ្នកសង្កេតការ មានភារៈកិច្ចចុះពិនិត្យជាក់ស្តែងដល់មូលដ្ឋានផលិតកម្ម ក្រោយពេលទទួលពាក្យរបស់អតិថិជនមួយថ្ងៃក្រោមកិច្ចចាត់ចែងរបស់ប្រធានច្រក រួចផ្តល់យោបល់ជូនសាមីស្ថាប័នរៀងខ្លួន ដើម្បីបញ្ជាក់ឯកភាពលើពាក្យសុំតាមកាលកំណត់ដូចមានចែងខាងលើ ។

ប្រធានច្រកចេញ-ចូលតែមួយត្រូវរាយការណ៍ជាប្រចាំពីសកម្មភាពការងារក្នុងរង្វង់ច្រកចេញ-ចូលតែមួយទៅស្ថាប័នពាក់ព័ន្ធ និងមានសិទ្ធិសម្រេចលើករណីដែលមានការរាំងស្ទះដោយប្រការណាមួយជាយថាហេតុ មុននឹងបញ្ជូនពាក្យ សុំរបស់អតិថិជនមកក្រសួង ។

ជាពិសេសប្រធានច្រកចេញ-ចូលតែមួយត្រូវទំនាក់ទំនងឱ្យបានជិតស្និទ្ធបំផុតជាមួយលេខាធិការដ្ឋាន នៃអនុគណៈកម្មាធិការសហគ្រាសធុនតូច និងមធ្យម ដើម្បីលេខាធិការដ្ឋានមានមូលដ្ឋានរាយការណ៍បន្តជូនប្រធាន អនុគណៈកម្មាធិការសហគ្រាសធុនតូច និងមធ្យមធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល

សេចក្តីណែនាំនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាល់សេចក្តីណែនាំពីមុន ដែលផ្ទុយពីនេះ ចាត់ទុកជានិរាករណ៍ ។

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ស៊ុយ សែម

<u>ចម្លងជូន :</u>

- .ទីស្តីការគណៈរដ្ឋមន្ត្រី
- .ក្រសួងមហាផ្ទៃ
- .ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- . ក្រសួងបរិស្ថាន
- .សាលាក្រុងភ្នំពេញ
- .គ្រប់សាលាខ័ណ្ឌក្នុងរាជធានីភ្នំពេញ
- .មន្ទីរបរិស្ថានក្រុងភ្នំពេញ

  "ដើម្បីជាពត៌មាន និងសហការអនុវត្ត"
- .មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលក្រុងភ្នំពេញ

  "ដើម្បីអនុវត្ត"
- .ឯកសារ.កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣*៨

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ.០០៦........សរណន.សអយ

សារាចរណែនាំ
ស្តីពី
ការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល

ដើម្បីអនុវត្តអោយមានប្រសិទ្ធភាពតាមមាត្រា ៣ នៃអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមធ្វើការណែនាំអនុវត្តដូចតទៅ :

I- របៀបគណនាប្រាក់សោធនថ្មីរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ

និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបានទទួលប្រាក់សោធនកន្លងមក ត្រូវបានកែសំរួលប្រាក់សោធនតាមការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ដោយគណនាតាមរូបមន្តដូចខាងក្រោម :

ប្រាក់សោធនសរុបប្រចាំខែថ្មី-ប្រាក់សោធនសុទ្ធសាធប្រចាំខែចាស់+ ១៥%នៃប្រាក់សោធនសុទ្ធសាធប្រចាំខែចាស់ + ប្រាក់ឧបត្ថម្ភផ្សេងៗ

- ចំពោះនិវត្តជនដែលមានប្រាក់សោធនសុទ្ធសាធប្រចាំខែទាបជាងប្រាក់បៀវត្សមូលដ្ឋានអប្បបរមានៃតារាងកាំ-ប្រាក់របស់សាមីខ្លួន ការគណនាប្រាក់ដំឡើង ១៥ % នៃប្រាក់សោធនសុទ្ធសាធគឺត្រូវយកប្រាក់បៀវត្សមូលដ្ឋានអប្បបរមានោះគុណនឹង១៥ % ។

- ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលមានប្រាក់សោធនសុទ្ធសាធប្រចាំខែទាបជាង ៥០%នៃប្រាក់បៀវត្សមូលដ្ឋានអប្បបរមានៃតារាងកាំប្រាក់របស់សាមីខ្លួន ការគណនាប្រាក់ដំឡើង ១៥% នៃប្រាក់សោធនសុទ្ធសាធគឺត្រូវយក ៥០% នៃប្រាក់បៀវត្សមូលដ្ឋានអប្បបរមានោះគុណនឹង ១៥% ។

ឧទាហរណ៍ទី ១ :

និវត្តជនម្នាក់មានតារាងកាំប្រាក់ ឃ១.១= ៥២ ៥០០រ០០ ។ ពេលចូលនិវត្តន៍គាត់មានភាគរយប្រាក់សោធននិវត្តន៍ស្មើនឹង ៨០%នៃបៀវត្សមូលដ្ឋានរបស់គាត់ ។មុនពេលធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល គាត់មានប្រាក់សោធន

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អាគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ,ទូរសព្ទ /ទូរសារៈ (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726086

និវត្តន៍សុទ្ធសាធប្រចាំខែចំនួន ៥៧ ៧៥០៖០០ ។ ដូច្នេះការគណនាប្រាក់សោធននិវត្តន៍របស់គាត់គឺៈ

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ៥២ ៥០០៖០០ x ៨០% = ៤២ ០០០៖០០
- ប្រាក់បៀវត្សមូលដ្ឋានអប្បបរមានៃតារាងកាំប្រាក់ ឃ១.៦ = ៤២ ៣០០៖០០
- ប្រាក់បន្ថែមអោយស្មើនឹងបៀវត្សមូលដ្ឋានអប្បបរមា = ៣០០៖០០
- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែស្មើនឹងបៀវត្សមូលដ្ឋានអប្បបរមា = ៤២ ៣០០៖០០
- ប្រាក់បង្គ្រប់ = ១៥ ០០០៖០០
- ប្រាក់បន្ថែមអោយស្មើប្រាក់សោធននិវត្តន៍ចាស់ = ៤៥០៖០០
- ប្រាក់ដំឡើង ១៥% នៃប្រាក់សោធននិវត្តន៍សុទ្ធសាធ ៤២ ៣០០៖០០ x ១៥% = ៦ ៣៤៥៖០០
- ប្រាក់សោធននិវត្តន៍សុទ្ធសាធថ្មី ៤២ ៣០០៖០០ + ៦ ៣៤៥៖០០ = ៤៨ ៦៤៥៖០០

ដូច្នេះប្រាក់សោធននិវត្តន៍ប្រចាំខែដែលត្រូវទទួល=៤៨ ៦៤៥៖+១៥ ០០០៖+៤៥០៖ = ៦៤ ០៩៥៖០០

ឧទាហរណ៍ទី ២ៈ

ជនបាត់បង់សម្បទាវិជ្ជាជីវៈម្នាក់មានតារាងកាំប្រាក់ គ៣-១៤ = ៤៥ ០០០៖០០ ។ ពេលចូលបាត់បង់សម្បទា-វិជ្ជាជីវៈ គាត់មានភាគរយប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ស្មើនឹង ៦៥% នៃបៀវត្សមូលដ្ឋានរបស់គាត់ ។ ដូច្នេះការគណនាប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈរបស់គាត់គឺៈ

- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសុទ្ធសាធប្រចាំខែ ៤៥ ០០០៖០០ x ៦៥% = ២៩ ២៥០៖០០
- ៩០% នៃប្រាក់បៀវត្សមូលដ្ឋានអប្បបរមា គ៣.១៤ =៤៥ ០០០៖០០ x ៩០% = ៤០ ៥០០៖០០
- ប្រាក់បន្ថែមអោយស្មើនឹង ៩០% នៃបៀវត្សមូលដ្ឋានអប្បបរមា = ១១ ២៥០៖០០
- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសុទ្ធសាធប្រចាំខែស្មើនឹង ៩០% នៃបៀវត្សមូលដ្ឋានអប្បបរមា

  = ៤០ ៥០០៖០០
- ប្រាក់ដំឡើង ១៥% នៃប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសុទ្ធសាធ

  ៤០ ៥០០៖០០ x ១៥% = ៦ ០៧៥៖០០

ដូច្នេះប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែដែលត្រូវទទួល

៤០ ៥០០៖០០ + ៦ ០៧៥៖០០ = ៤៦ ៥៧៥៖០០

ការបូកបន្ថែម ១៥ % នៃប្រាក់សោធនសុទ្ធសាធរបស់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវអនុវត្តចាប់ពីខែ មករា ឆ្នាំ ២០០៥ នេះតទៅ ។

II-របៀបគណនាប្រាក់សោធនរបស់មន្ត្រីរាជការចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អាគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ,ទូរស័ព្ទ /ទូរសារៈ (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726086

ក- ប្រាក់សោធនរបស់មន្ត្រីរាជការដែលត្រូវចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ត្រូវបានបូកបន្ថែម១៥%នៃប្រាក់សោធនសុទ្ធសាធប្រចាំខែរបស់សាមីជន ដោយគណនាតាមរូបមន្តដូចខាងក្រោម :

ប្រាក់សោធនសរុបប្រចាំខែ - ប្រាក់សោធនសុទ្ធសាធប្រចាំខែ + ១៥% នៃប្រាក់សោធនសុទ្ធសាធប្រចាំខែ + ប្រាក់ឧបត្ថម្ភផ្សេងៗ

ប្រាក់សោធនសុទ្ធសាធប្រចាំខែត្រូវគណនាលើប្រាក់បៀវត្សមូលដ្ឋានចាស់ ។

ខ-ប្រាក់សោធនរបស់មន្ត្រីរាជការដែលត្រូវចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៥ តទៅ ត្រូវគណនាតាមរូបមន្តដូចខាងក្រោម :

ប្រាក់សោធនសរុបប្រចាំខែ - ប្រាក់សោធនសុទ្ធសាធប្រចាំខែ + ប្រាក់ឧបត្ថម្ភផ្សេងៗ

ប្រាក់សោធនសុទ្ធសាធប្រចាំខែត្រូវគណនាលើប្រាក់បៀវត្សមូលដ្ឋានថ្មី ។

ឧទាហរណ៍ ទី ៣

មន្ត្រីម្នាក់មានតារាងកាំប្រាក់ ឃ១-១= ៦០ ៣៧៥៛០០ ត្រូវចូលនិវត្តន៍នៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៥ ។ពេលចូលនិវត្តន៍គាត់មានភាគរយសោធននិវត្តន៍ស្មើនឹង ៨០% ។ មុនពេលធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល បើគណនាប្រាក់សោធននិវត្តន៍សុទ្ធសាធរបស់គាត់គឺមានចំនួន ៦៤ ០៩៥៛០០ ។ ដូច្នេះការគណនាប្រាក់សោធននិវត្តន៍សុទ្ធសាធរបស់គាត់គឺ:

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ៦០ ៣៧៥៛០០ x ៨០% = ៤៨ ៣០០៛០០
- ប្រាក់បៀវត្សមូលដ្ឋានអប្បបរមា ឃ១-៦ = ៤៨ ៦៤៥៛០០
- ប្រាក់បន្ថែមអោយស្មើនឹងបៀវត្សមូលដ្ឋានអប្បបរមា = ៣៤៥៛០០
- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែស្មើនឹងបៀវត្សមូលដ្ឋានអប្បបរមា = ៤៨ ៦៤៥៛០០
- ប្រាក់បង្គ្រប់ = ១៥ ០០០៛០០
- ប្រាក់បន្ថែមអោយស្មើប្រាក់សោធននិវត្តន៍ចាស់ = ៤៥០៛០០

ដូច្នេះប្រាក់សោធននិវត្តន៍ប្រចាំខែដែលត្រូវទទួល=៤៨ ៦៤៥៛ + ១៥ ០០០៛ + ៤៥០៛ = ៦៤ ០៩៥៛០០

គ-ទម្រង់បែបបទស្នើសុំប្រាក់សោធនថ្មី

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង ត្រូវធ្វើលិខិតស្នើសុំកែប្រែប្រាក់សោធនប្រចាំខែរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ មកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយភ្ជាប់មកជាមួយនូវៈ

- តារាងបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ប្រចាំខែចុងក្រោយ ចំនួន ០១ ច្បាប់
- តារាងបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈថ្មី ចំនួន ០១ ច្បាប់

បន្ទាប់ពីបានទទួលការយល់ព្រមជាគោលការណ៍ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា លើតារាង

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អាគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ,ទូរស័ព្ទ /ទូរសារ: (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726086

ប្រាក់សោធនថ្មីមក ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង មានសិទ្ធិចុះហត្ថលេខានៅលើទំព័រ "ប្តូរប្រាក់បៀវត្សគិតពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥" របស់សៀវភៅនិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ។

សារាចរណែនាំលេខ ០០៣ សរណន.សអយ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៥ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការកែប្រែឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ត្រូវចាត់ទុកជានិរាករណ៍ ។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ សីហា ឆ្នាំ ២០០៥

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទៀ បាញ់
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- គ្រប់សាលា ខេត្ត - ក្រុង
  "ដើម្បីជូនជ្រាបជាពតិមាន"
- គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល
- គ្រប់មន្ទីរ ស អ យ ខេត្ត - ក្រុង
  "ដើម្បីសហការអនុវត្ត"
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៧៦ ពណ.នតក

ភ្នំពេញថ្ងៃទី ០៥ ខែសីហា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **មាស ចយ ត្រេឌីង**

MEAS JOY TRADING Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7928 /05P ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៥

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :
- លោក **មាស ចយ** ប្រធានក្រុមប្រឹក្សាភិបាល
- លោក **មាស សុខ** អភិបាល
- លោក **ទិន ឆាំ** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២០០ EoZ ផ្លូវលេខ ១០៧ ក្រុម ៤៦ មណ្ឌល ៨ សង្កាត់អូរឫស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការដួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដឹកជញ្ជូនសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីស្តីទី

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៨២៧ ពណ.ឧតក

ភ្នំពេញថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ភី.អិល ត្រេឌីង**

P. L TRADING Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 7942/05P** ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **គី ស៊ីវគីម** ប្រធានក្រុមប្រឹក្សាភិបាល

លោក **ឈិន ហុង** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១០៦៩ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងទទួលបញ្ញើ...

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម: រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ជ.រដ្ឋមន្ត្រីស៊ីនី

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៥៣១ ពណ.ឧតក

ភ្នំពេញថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ស៊ី អាយ ឌី អាយ**

C I D I Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 7939 /05P** ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៥

មានទម្រង់ជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក LEE SUNG MIN ប្រធានក្រុមប្រឹក្សាភិបាល
លោក សុ ឆនាក់ អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣៧Eo ផ្លូវលេខ ៥៩៤ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសនាំចូលប្រេងឥន្ធនៈ ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការដួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកក់រៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស-សេវាបញ្ជូន និងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារស្ថាន ផ្តល់។

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម: រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៚

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ជំនួសរដ្ឋមន្ត្រី

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៥៣៤ ពណ.នគក

ភ្នំពេញថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខ្មែរ យូនីវើសល**

KHMER UNIVERSAL Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 7945/05P** ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **គុយ ទីសារ័ត្ន** ប្រធានក្រុមប្រឹក្សាភិបាល

លោក **ឡុង ចន្ណា** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៥២K ផ្លូវលេខ ១១០ (សហព័ន្ធរុស្ស៊ី) សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកក័រែដឹងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីស្តីទី

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៨៣៥ ពណ.នគក

ភ្នំពេញថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហុង សាន ហ្វ័រវើឌីង**
HONG SAN FORWARDING Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7937/05P ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **លី ហុង**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៥០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៣៦សេ ផ្លូវលេខ១៥៥ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម : -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ចូននិងចែកចាយទំនិញ
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដូសជុលសំភារៈទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួរ ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ
-សាងសង់ ជួសជុល អាគារស្នាក់នៅ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីស្ដីទី

ជាម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
